**សម្ភាសន៍ជាមួយឈ្មោះ ឈឹម ផន ភេទប្រុស អាយុ៧២ឆ្នាំ**
**មុខងារជំនាន់ខ្មែរក្រហមៈអនុប្រធានឃុំព្រះនេត្រព្រះ**
**ស្រុកកំណើតនៅភូមិព្រៃកប្ញស្សី ឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្តាល**
**រស់នៅភូមិកណ្តាល ឃុំអូរស្រឡៅ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ**
**ថ្ងៃទី១១ខែតុលា ឆ្នាំ២០១១**
**សម្ភាសន៍ដោយៈ ឡុង ដានី និង វ៉ាន់ថាន់ ពៅដារ៉ា**
**០១:៥៨:០៧**
**៥៧ទំព័រ**

ដានី : អឺចឹងអ៊ឹដឹបូងខ្ញុំចង់ស្គាល់ឈ្មោះអ៊ី អ៊ីឈ្មោះអីដែរ?

ផន : បាទ! ឈឹម ផន ។

ដានី : អឺចឹងខ្ញុំចង់ណែនាំខ្លួនពួកខ្ញុំម្តងទៀតឲ្យកាន់តែច្បាស់ណាសអ៊ី?

ផន : បាទ ។

ដានី : ខ្ញុំឈ្មោះដានី ហើយគាត់ដារ៉ា មកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយមជ្ឈមណ្ឌលឯកសារកម្ពុជាមានទីតាំងនៅទីក្រុងភ្នំពេញណាសអ៊ី ហើយមជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹងធ្វើការស្រាវជ្រាវប្រមែប្រមូលឯកសារដែលទាក់ទងហ្នឹងសម័យបីឆ្នាំជាពិសេសពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ណាស់អ៊ី ។

ផន : បាទ ។

ដានី : ហើយយើងប្រមូលឯកសារនេះដើម្បីទុកក្មេងជំនាន់ក្រោយ ទុកអ្នកសិក្សាស្រាវជ្រាវ ប្រជាជនយើងក៏ដោយឲ្យតែអ្នកចង់ដឹងពីរបបបីឆ្នាំហ្នឹងគេចង់អាន អាចទៅមើលឬអានបាននៅលើវែបសាយរបស់យើងខាងមជ្ឈមណ្ឌលឯកសារកម្ពុជារកបានណាសអ៊ី ។ ហើយខ្ញុំមកជួបអ៊ីនេះដូចថាពួកខ្ញុំចង់ដឹងពីបទពិសោធន៍ពីជីវិតរបស់អ៊ីដែលធ្លាប់ឆ្លងកាត់សម័យសង្គ្រាមក្នុងសម័យបីឆ្នាំដើម្បីយកទៅចងក្រងទុកឲ្យក្មេង សំរាប់ឲ្យក្មេងជំនាន់ក្រោយ ឲ្យអ្នកស្រាវជ្រាវ ដូចខ្ញុំបានជំរាបអ៊ីមិញហ្នឹង ។

ផន : បាទ ។

ដានី : អឺចឹងខ្ញុំចង់សួរទាក់ទងហ្នឹងជីវិតអ៊ី តើអ៊ីអនុញ្ញាតឲ្យខ្ញុំសួរនាំដែរទេ?

ផន : បាទ!សួរចុះអត់មានអីទេ ។

ដានី : អ៊ីអត់មានចំងល់អីទេចឹង?

ផន ៖ បាទ!អត់មានចំងល់អីទេ ។

ដានី ៖ បាទ!អីចឹងខ្ញុំសុំស្គាល់ឈ្មោះមួយសារទៀត?

ផន ៖ បាទ! ឈឹម ផន ។

ដានី ៖ ឈឹម ហ្អឺ?

ផន ៖ បាទ! ឈឹម ផន ។

ដានី ៖ ឈឹម ផន ។ អ៊ឹអាយុប៉ុន្មានហើយសព្វថ្ងៃ?

ផន ៖ អាយុ៧២ហើយ ។

ដានី ៖ អាយុ៧២ ហើយ! អ៊ឹស្រុកកំណើតកើតជាអីនៅឯណាដែរ?

ផន ៖ បាទ!នៅភូមិព្រៃកប្បស្សី ឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្តាល ។

ដានី ៖ សព្វថ្ងៃអ៊ឹរស់នៅភូមិឃុំស្រុកអីដែរ?

ផន ៖ សព្វថ្ងៃនេះ?

ដានី ៖ បាទ ។

ផន ៖ សព្វថ្ងៃនៅភូមិកណ្តោល ឃុំអូរស្រឡៅ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

ដានី ៖ សព្វថ្ងៃអ៊ឹប្រកបមុខរបរកស៊ីអីដែរ?

ផន ៖ សព្វថ្ងៃធ្វើស្រែ ហើយចំការខ្លះ ។

ដានី ៖ ធ្វើស្រែ ធ្វើចំការអ៊ឹ?

ផន ៖ បាទ ។

ដានី ៖ ប្រពន្ធអ៊ឹគាត់ឈ្មោះអីដែរ?

ផន ៖ ឈ្មោះ ជួន រិន ។

ដានី ៖ ជួន រិន?

ផន ៖ បាទ!

ដានី ៖ សព្វថ្ងៃគាត់អាយុប៉ុន្មានដែរ?

ផន ៖ អាយុគាត់ ឆ្នាំថោះ មិនដឹងអាយុប៉ុន្មានប្រហែលហាជាង ហុកហើយដឹង ឆ្នាំថោះ ។

ដានី ៖ ប្អូនអ៊ឹប៉ុន្មានឆ្នាំទៅ?

ផន ៖ ប្អូនខ្ញុំប្រហែលចង់ម៉ាជួរ ១២ឆ្នាំ ១១ឆ្នាំ ។

ដានី ៖ ប្អូន១១ឆ្នាំហ្នឹអ៊ឹ?

ផន ៖ បាទ ។

ដានី ៖ ចុះអ៊ឹមានកូនចៅប៉ុន្មាននាក់ដែរ?

ជន ៖ កូនចៅទាំងអស់វា៨នាក់ តែស្លាប់ម្នាក់នៅសល់៧នាក់ ។

ដានី ៖ បាទ!ស្លាប់ម្នាក់នៅសល់៧ហ្អី?

ជន ៖ បាទ ។

ដានី ៖ ស្រីប៉ុន្មានប្រុសប៉ុន្មានទៅ?

ជន ៖ ស្រីបួន ប្រុសបី ។

ដានី ៖ ស្រីបួន ប្រុសបី?

ជន ៖ បាទ!នេះនៅរស់ណាស និយាយតែនៅរស់ ។

ដានី ៖ ស្លាប់ប្រុសឬស្រី?

ជន ៖ ស្រីទៀត ស្លាប់ស្រីបងគេទៀត ។

ដានី ៖ ចុះឪពុកអ៊ំឈ្មោះអីដែរ?

ជន ៖ ឪពុកខ្ញុំឈ្មោះ ឈឹម ជន ។

ដានី ៖ ឈឹម ជន?

ជន ៖ បាទ ។

ដានី ៖ គាត់នៅរស់ឬស្លាប់ហើយ?

ជន ៖ បាទ! គាត់អនិច្ចកម្មហើយ ។

ដានី ៖ គាត់ស្លាប់តាំងពីកាលណាដែរ?

ជន ៖ ហ្អស!មើលតាំងពីខ្ញុំនៅសិក្សាបឋមសិក្សា ។

ដានី ៖ គាត់ស្លាប់ដោយសារអីទៅ?

ជន ៖ អានេះជំងឺ ដោយសារជំងឺក្រពះ ។

ដានី ៖ ជំងឺក្រពះ?

ជន ៖ បាទ ។

ដានី ៖ ចុះម្តាយអ៊ំគាត់ឈ្មោះអីទៅ?

ជន ៖ ម្តាយឈ្មោះ មិន ឡាច ។

ដានី ៖ មិន ឡាច ។ គាត់ខូចហើយដែរ?

ជន ៖ បាទ! គាត់ខូចហើយ ។

ដានី ៖ គាត់ខូចឆ្នាំណាទៅ?

ជន ៖ ហ្អស!មុនឪពុកខ្ញុំទៀត ។

ដានី ៖ មុនទៀត?

ជន ៖ បាទ!កាលនោះមានបងប្អូនពីរនាក់នោះ តែវានៅតូចៗ គាត់អនិច្ចកម្មទៅ ខ្ញុំមិនសូវដឹងដែរ តែដឹងថាមានម្ដាយដែរ ដឹងម្ដាយ ។

ដានី ៖ ចុះអ៊ំបងប្អូនបង្កើតប៉ុន្មាននាក់ទៅ?

ជន ៖ ខ្ញុំបងប្អូនបង្កើតតែពីរនាក់ទេ ។

ដានី ៖ តែពីរនាក់ទេ?

ជន ៖ បាទ!គាត់អនិច្ចកម្មនៅក្នុងសង្គ្រាម មិនដឹងទៅណាមកណារកអត់ឃើញទេ ។

ដានី ៖ ពីរនាក់ហ្នឹងស្រី...?

ជន ៖ បាទ!មានតែខ្ញុំហើយនិងគាត់ហ្នឹង ស្រីមួយប្រុសមួយតែប៉ុណ្ណឹងឯង ។

ដានី ៖ តែពីរនាក់អ៊ំប្រុស ហើយគាត់ស្រី?

ជន ៖ បាទ ។

ដានី ៖ អ៊ំបង?

ជន ៖ បាទ!បងគេបង្អស់ ។

ដានី ៖ ហើយប្អូនស្រី?

ជន ៖ ប្អូនស្រី ។

ដានី ៖ ហើយបាត់តាំងពីអង្កាល់ទៅ?

ជន ៖ អូ!បាត់តាំងពីអាកាលដែលយើងកំពង់រឹកវរហ្នឹងក្នុងឆ្នាំអាមេរិកកាំងធ្លាក់ សង្គ្រាមអាមេរិកាំង ហ្នឹង ។

ដានី ៖ សង្គ្រាមពីឆ្នាំ៧០ដល់៧៥ហ្នឹងហ្អី?

ជន ៖ បាទ ។

ដានី ៖ បាត់នៅម្ដុំណា?

ជន ៖ មិនដឹងថាកាលនោះគេបញ្ជូនមិនដឹងគេជម្លៀសមក តែដឹងថានៅក្រុងភ្នំពេញ ។

ដានី ៖ គាត់ឈ្មោះអីទៅមីង?

ជន ៖ ឈ្មោះរ៉ែន ។

ដានី ៖ ឈ្មោះ រ៉ែន ?

ជន ៖ បាទ! ឈឹម រ៉ែន ។

ដានី ៖ បាទ!អ៊ីចឹងខ្ញុំចង់ឲ្យអ៊ំរៀបរាប់ពីជីវិតរបស់អ៊ំណាស តាំងពីអ៊ំក្មេងៗមកអ៊ំនៅឯណា រៀនសូត្រ អីនៅសាលាណាខ្លះ ហើយរៀនដល់ត្រឹមណា ហើយតាំងពីអ៊ំឈប់រៀនមកអ៊ំធ្វើអី ហើយ រហូតមកដល់សម័យបីឆ្នាំ ហើយក្រោមមកទៀតអ៊ំ ។

ផន ៖ បាទ! តាំងពីខ្ញុំនៅតូច ខ្ញុំរៀននៅវត្តកំពង់សំបួរ ដល់ពេលនោះខ្ញុំក៏ឡើងមករៀននៅភ្នំពេញ ដល់ឡើងមកនៅភ្នំពេញខ្ញុំរៀននៅសាលាព្រះយុគន្ធរ បានបីឆ្នាំ ពេលនោះឪពុកខ្ញុំក៏អនិច្ចកម្មទៅ ។ ដល់គាត់អនិច្ចកម្មចឹងទៅ ខ្ញុំក៏អត់ប្រាក់រៀន ហើយប្អូនក៏នៅស៊ីឈ្នួលគេនៅភ្នំពេញចឹងទៅ ប្អូនស្រីណាស ។ គាត់នៅក្នុងក្រុងភ្នំពេញចឹងទៅ ដល់ពេលធម្មតាទេ អ្នកនៅស៊ីឈ្នួលគេ ហើយគ្នាក្មេងស្រី ហើយខ្ញុំកំពុងតែនៅសិក្សាកំពុងពេញចូលចិត្តរៀន ដល់ចឹងទៅប្អូនខ្ញុំក៏ខ្វះប្រាក់ឲ្យ ពេលនោះខ្ញុំក៏សំរេចចិត្តថា នៅអីចឹងមិនបានទេ ទាល់តែដើរចេញមករកការងារធ្វើ ។ ដល់រកការងារធ្វើចឹងទៅ ខ្ញុំក៏ចេញមកបាត់ដំបង ។ ពេលខ្ញុំចេញមកបាត់ដំបង ខ្ញុំអត់មានលុយអីទេ ហើយប្អូនខ្ញុំក៏មិនដឹងថាខ្ញុំទៅណាដែរ ។ ខ្ញុំមកនៅបាត់ដំបង ស្នាក់នៅបាត់ដំបងហើយខ្ញុំក៏រកស៊ីឈ្នួលគេដែរ ដល់ខ្ញុំស៊ីឈ្នួលគេជាមួយចិននោះទៅ ចិននោះក៏ស្រលាញ់វាទុកចិត្តយើងចឹងទៅ ក៏គេឲ្យខ្ញុំបង្រៀនកូនគេ ដល់ខ្ញុំបង្រៀនភាសាបារាំងហ្នឹងខ្លះតិចតួចទៅ ហើយភាសាខ្មែរយើងនឹង ។ ដល់នេះគាត់ក៏ឲ្យប្រាក់ខែខ្ញុំបានទទួលទានទៅ ប្រាក់ខែហ្នឹងម៉ាខែ៦០០ ។

ដារ៉ា ៖ ៦០០ រៀលហ្នឹង?

ផន ៖ បាទ!៦០០រៀលតែជំនាន់ខ្ញុំវាថ្លៃណាស ។ ដល់ចឹងទៅខ្ញុំដូចថានៅជាមួយគេវាមិនបានទេ វាដូចថាចិត្តហ្នឹងចេះតែចង់មានចង់បានដូចថារពិលដែចង់ធ្វើអីផ្សេង ខ្ញុំក៏ចេញមកស៊ីឈ្នួលគេមួយកន្លែងទៀត ។ ស៊ីឈ្នួលគេមួយកន្លែងទៀតហ្នឹងទៅ គាត់ក៏ឃើញខ្ញុំធ្វើការម៉ឺងម៉ាត់ចឹងគាត់ក៏លើកកូនឲ្យ ។ ដល់គាត់លើកកូនឲ្យ ខ្ញុំក៏ដូចថា បានកូនហ្នឹងទៅ ហើយបែកពីគាត់ ខ្ញុំក៏រកស៊ីធម្មតាពីរនាក់ប្ដីប្រពន្ធចឹងទៅ គាត់ជួយជាស្បៀងខ្លះ ប្រាក់កាសអីខ្លះចឹងទៅ ដីអីខ្លះខ្ញុំក៏ដាំបន្លែ ។ ពេលនោះហើយកំពុងដាំបន្លែដែលយើងកំពុងតែវ៉ៃខ្លាំងពួកអាមេរិកកាំងហ្នឹងណាស ។ ខ្ញុំពួកខាងក្នុង ពួកខាងខ្មែរក្រហមយើងនេះគេដាក់ខ្ញុំនៅខាងសេដ្ឋកិច្ច សេដ្ឋកិច្ចបន្លែណាស ហើយខាងយើងខាងក្រៅខាងរដ្ឋាភិបាល លន់ នល់ នេះចាត់ខ្ញុំឲ្យធ្វើមេហាសិបខ្នងណាសតែខ្ញុំមិនដឹងស្អីទេ ។ អីចឹងខ្ញុំយកមកវិភាគទាំងពីរនេះទៅឃើញថាបើខ្ញុំនៅតទៅទៀតខ្ញុំត្រូវមានគ្រោះថ្នាក់អីចឹងខ្ញុំរត់ទៅនៅខាងភូមិប្រពន្ធនៅខាងឪម៉ាល់ផ្លូវកាត់ ។ ដល់ទៅនៅឪម៉ាល់ផ្លូវកាត់ចឹងទៅ ក៏អីណោះក៏គេចូលខ្មែរក្រហមស៊ុប អីចឹងខ្ញុំថា ហ្អស!ចប់បាត់ ឯងថាចេញមកឲ្យផុតនៅឪម៉ាល់ផ្លូវកាត់រកបងប្អូនមាមីងខាងប្រពន្ធហ្នឹងដើម្បីរកសេចក្ដីសុខ ស្រាប់តែដល់ចឹងទៅគេថានៅមិនបានទេត្រូវចូកលព្រៃទៀត ក៏ខ្ញុំចូលនឹងគេដែរទៅ ។ ដល់ចូលទៅគេដាក់ខ្ញុំនៅខាងរកម្ហូបរហូតដល់ឆ្នាំ៧៥ គេដាក់ខ្ញុំឲ្យនៅគង្វាលគោ ដល់នេះទៅមានអាចោរមកលួចគោរបស់រដ្ឋខ្មែរក្រហមនេះណាស ។

ដារ៉ា៖ នៅឯណាទៅពូ?

ជន ៖ នៅខាងយើងម៉ាដូវវាលស្បូវ កៀនស្បូវនេះ ខាងសំបូរស្នាមមាសយើងចុះមក នៅកៀនស្បូវនេះម៉ងណាស ។ មកហ្នឹងពួកនោះមកកៀងគោទៅគេចង់ចាប់ខ្ញុំណាស គេថាខ្ញុំសតិសម្ព័ន្ធជាមួយខ្មាំង ឲ្យគេចូលមកយកគោ ។ ខ្ញុំក៏ទៅរាយការណ៍ប្រាប់គេចឹងទៅក៏ដូចថាគុណបុណ្យជួយដែរ គេក៏អត់យកទោសពៃអីទេ ។ គេថាមិនអីទេ គេនៅតាមដានយើងបន្តទៀតណាស ។ ដល់ក្រោយមកគេហៅបញ្ចប់ណាសអាហ្នឹងណាស ម៉ាចប់វៃហើយ ពួកនេះយើងហ្នឹងវៃ ពួកខ្មែរក្រហម ។ វៃ បានភ្នំពេញអីចឹងហើយណាស ខ្ញុំនេះក៏...ហួស! បានឯករាជ្យហើយ គេក៏បញ្ជូនខ្ញុំមក ពីក្នុងព្រៃវាលស្បូវមកទីម៉ាល់ដូវគាត់នេះវិញចឹងទៅ ខ្ញុំក៏មកតាមគេចឹងមក គេក៏ចាត់តាំងខ្ញុំហើយ គេចាត់តាំងខ្ញុំឲ្យធ្វើជាភូមិ ដល់ភូមិចឹងមកបានប៉ុន្មានម៉ាខែ ស្រាប់តែគេចាត់តាំងខ្ញុំឲ្យទៅជាស្អី សមាជិកឃុំ ។

ដារ៉ា ៖ ឃុំអីគេអ៊ី?

ជន ៖ ឃុំព្រះនេត្រព្រះយើងនេះ គេឲ្យធ្វើជាស្អីទេ សមាជិកឃុំ ដល់ចឹងទៅធ្វើបានប្រហែលជាមួយឆ្នាំបានខាងបច្ចឹមគេមក គេមកហ្នឹងវាច្របូកច្របល់គ្នាគេចាប់ មិនដឹងអ្នកណាអ្នកណីទេ ខ្ញុំក៏ពុទ្ធោរយកគ្នាហើយ ។ ខ្ញុំនឹកឃើញក្នុងចិត្តថា បើអញធ្វើជាអ្នកចេះដឹង អញគ្រោះថ្នាក់ ។ ខ្ញុំក៏សន្មត់ខ្លួនខ្ញុំថា ខ្ញុំមិនមែនជាអ្នកចេះទេ ។ គេចាប់ផ្ដើមពួកបច្ចឹមមកគេធ្វើប្រវត្តិរូបខ្ញុំ គេសួរថាអ្នកឯងរៀនបានថ្នាក់ទីប៉ុន្មានអីប៉ុន្មាន ខ្ញុំក៏...មនុស្សល្ងង់ ខ្ញុំធ្វើជាមិនដឹងអី ។

ដារ៉ា ៖ ខ្ញុំសុំកាត់បន្តិចអ៊ី ពេលដែលអ៊ីមកដល់ធ្វើជាសមាជិកឃុំព្រះនេត្រព្រះហ្នឹងណាស អាហ្នឹងពេលដែលចប់ ខ្មែរក្រហមឡើងកាន់អំណាចហើយណាស?

ជន ៖ បាទ ។

ដារ៉ា ៖ ពេលហ្នឹងមានប្រធានឃុំ អនុប្រធានឃុំហើយនៅពេលអ៊ីមកធ្វើសមាជិក?

ជន ៖ គេមានហើយ មាន តា ក្រុក សន ហើយខ្ញុំក្រោមគេ ។

ដារ៉ា ៖ អីចឹងបានន័យថាក្រោមគេក្នុងចំណោមបីនាក់?

ជន ៖ បីនាក់!មានម្នាក់ទៀត តា ចាម មួយទៀត ។ អាហ្នឹងក្រោយទេណាស ។

ដារ៉ា ៖ បាទ!មាន តា ក្រុក តា សន តាណាមមួយទៀត?

ជន ៖ ខ្ញុំនេះ ហើយ តា ចាម ។

ដារ៉ា៖ អីចឹងបានពួកបច្ចឹមមក ។

ជន ៖ ដល់ពួកបច្ចឹមមកចឹងគេដណ្ដើមនាទីគ្នាណាស គេបំរុងទំលាក់ពួកខ្ញុំ គេចាត់តាំងខ្ញុំឲ្យមកក្លួរគេចេញឲ្យមកក្លួរហើយខ្ញុំចេះតែធ្វើតាមបញ្ជារបស់គេចឹងទៅអត់មានគិតរឿងអីទេ គិតតែធ្វើ

ម៉ែៗអត់បានសំរាកទេ ដល់ចឹងវាអត់បាយអត់អីខ្លាំងចឹងទៅ ខ្ញុំក៏រាយរបាយការណ៍ឡើងមក ប្រាប់គេចឹងទៅ គេឲ្យយើងនៅជាក្រុមណាស នៅខាងភូរចឹង ។

ដារ៉ា ៖ អីចឹងអ៊ីគេឲ្យនៅគ្រប់គ្រងអ្នកភូរទាំងអស់?

ជន ៖ បាទ!អ្នកភូរ ។ ដល់គ្រប់គ្រងអ្នកភូរបានប្រហែលមួយខែជាង គេហៅខ្ញុំឡើងមកប្រជុំ ។

ដារ៉ា ៖ មកប្រជុំជាមួយអ្នកណា?

ជន ៖ ខាងឃុំហ្នឹងណាស ក្នុងបីនាក់ហ្នឹងគេឲ្យមកប្រជុំ គេបញ្ជូនមកប្រជុំនៅសាលាស្រុកទៀត ។

ដារ៉ា ៖ នៅដល់កន្លែងណាទៅសាលាស្រុកហ្នឹង?

ជន ៖ ស្រុកព្រះនេត្រព្រះហ្នឹង ។ ដល់ខ្ញុំឡើងមកប្រជុំ ប្រជុំហ្នឹងគណៈស្រុកគេចាត់តាំងខ្ញុំទៀតហើយ ។

ដារ៉ា ៖ គណៈស្រុកឈ្មោះអីកាលនោះ?

ជន ៖ មើល!កាលនោះឈ្មោះអីទេ អាត ហ្នឹងអនុទេ តា ខូ ហ្នឹងសមាជិកទេ ហើយ តា អីទៀតទេ ខ្ញុំភ្លេចដែរ ។

ដារ៉ា ៖ តា ម៉ោង?

ជន ៖ បាទៗ!ហ្នឹងហើយ តា ម៉ោង ហ្នឹងខាងនិរតីហើយ ។

ដារ៉ា ៖ អីចឹងមុនហ្នឹងទេ?

ជន ៖ មុនហ្នឹង ចាំមើលណាស មាន តា អាត តា ខូ... ។

ដានី ៖ តា ម៉ោង ពាយ័ព្យទេតើអ៊ី?

ជន ៖ បាទ! តា ម៉ោង... តា ម៉ោង ពាយ័ព្យហ្នឹង តែ តា ម៉ោង ក្រោយទេ ។ មួយទៀតនៅពីលើហ្នឹងទៀតហ្នឹងណាស រួចហើយបានមក តា ម៉ោង ។

ដារ៉ា ៖ នៅមានមុន តា ម៉ោង ហ្នឹងទៀត?

ជន ៖ បាទ!មានមុន តា ម៉ោងម្នាក់ទៀត បីនាក់ខ្ញុំចាំ ។ មាន តា អាត តា ខូ អាហ្នឹងដែលខ្ញុំចាំណាស ។ រាងស្តើង ឈ្មោះអីទេ! គាត់ហ្នឹងស្រុកដែរ ឈ្មោះអីទេ... ។

ដានី ៖ ម៉េចទៀតទៅអ៊ី?

ជន ៖ ដល់ចឹងទៅខ្ញុំក៏គេចាត់តាំងឲ្យខ្ញុំធ្វើចឹង គេរៀបចំដែនការឲ្យខ្ញុំមកខាងទំនប់ម្តង ។

ដារ៉ា ៖ ឈ្មោះ តា សំអាត ហ្នឹងអ៊ីហ្អី?

ជន ៖ បាទ!

ដានី ៖ ឈ្មោះ អន ម៉ោង?

ជន ៖ ខ្ញុំអត់ដឹងដែរ ខ្ញុំចាំតែ ខូ ហ្នឹងក៏គេសមាជិកស្រុកហ្នឹងដែរ ។

ដារ៉ា ៖ អីចឹងមុនហ្នឹងមានម្នាក់ទៀតហ្អីពេលអ៊ីទៅដល់ភូមហ្នឹងណាស?

ជន : បាទ!មិនមែន តា ម៉ោង ទេគាត់ក្រោយទេ ។

ដារ៉ា : ក្រោយទៀត ។

ជន : ក្រោយទៀត តែអាហ្នឹងនៅក្នុងក្រុមគាត់ដែរ ។

ដានី : ម៉េចទៀតទៅអ៊ី?

ជន : ដល់គេចាត់តាំងខ្ញុំមកខាងទំនប់ ទំនប់យើងនេះណាស ទំនប់ធំជាងគេទំនប់អីទេនៅភ្នំស្រុកណាស គេឲ្យខ្ញុំធ្វើអាត្រពាំងថ្មហ្នឹង គេឲ្យខ្ញុំទទួលខុសត្រូវនៅហ្នឹងៗ ខ្ញុំក៏ទទួលខុសត្រូវហ្នឹងទៅដល់ក្រោយមកទៀតបាន និរតីនេះគេទាញខ្ញុំមកវិញ គេឲ្យខ្ញុំមកនៅធ្វើស្រែ ធ្វើស្រែនៅព្រះនេត្រព្រះ ធ្វើស្រែចឹងទៅចាប់ផ្តើមយួនមកព្រឹបចឹងមក គេហៅពួកខ្ញុំទៅលើកដៃ លើកដៃដូចថាគេថាមានមិត្តណាស្ម័គ្រចិត្តទៅវៃយួននៅព្រំប្រទល់ដែនទេ? ខ្ញុំថា ម៉េចអីចេះ! លេងមែនទែនហើយតើ ម៉េចអីចឹង ខ្ញុំក៏នឹកក្នុងចិត្តថាបើទៅវៃយួននោះ មិនបានទេ មិនទៅទេ តែក្នុងចិត្តគិតថាមិនទៅ តែលើកដៃដែរ ដល់ពេលនោះលើកដៃ តែគេអត់យកទៅដែរ ខ្ញុំលើកដៃតែគេអត់យកទៅដែរ ។ ហើយគេសរសើរខ្ញុំទៀតថា ក្លាហានណាស តែបើក្នុងចិត្តអត់មានចង់ទៅទេ តែបើយើងមិនធ្វើអីចឹងដើម្បីរស់ ចេះតែគិតអីចឹង ។ នេះចូលរដ្ឋហើយ ដល់ពេលយួនបុកខ្លាំង គេចេញ ហើយខ្ញុំក៏ចេញនឹងគេដែរទៅ ។

ដានី : បាទ!អ៊ីខ្ញុំចង់បកទៅក្រោយអំបាញ់មិញបន្តិចអ៊ី កាលពីក្មេងអ៊ីថារៀននៅកំពង់សំបួរចឹងហ្អីអ៊ី?

ជន : បាទ!

ដានី : កាលនោះឆ្នាំណាទៅ?

ជន : ឆ្នាំមួយពាន់ប្រាំបួនរយ បើមិនហា ឬហុកទេនេះ ទេ!ហា ព្រោះខ្ញុំត្រូវប្រលងស៊ីវិការ ។

ដានី : អីចឹងអ៊ីរៀននៅកំពង់សំបួរដល់ថ្នាក់ទីប៉ុន្មាន?

ជន : អាហ្នឹងហៅឧត្តមដ្ឋាន ។

ដានី : ឧត្តមដ្ឋានថ្នាក់ទីប៉ុន្មានទៅអាហ្នឹង?

ជន : ដូចថា កុមារដ្ឋាន បរិវចនៈដ្ឋាន អទិកដ្ឋាន មជ្ឈិមដ្ឋានទី១ ទី២បានឧត្តមដ្ឋាននេះថ្នាក់ទី៦ ។

ដានី : អីចឹងរៀននៅកំពង់សំបួរដល់ថ្នាក់ទី៦?

ជន : បាទ!

ដានី : ទី៦អ៊ីប្រលងជាប់ទេ?

ជន : អត់ ។

ដានី : ប្រលងធ្លាប់?

ជន : បាទ ដល់ប្រលងធ្លាប់ខ្ញុំមករៀននៅអាសាលាព្រីវេយើងនៅភ្នំពេញ ។

ដានី ៈ រៀននៅសាលាព្រីវេ?

ជន ៈ បាទ! រៀនអាសាលាឈ្នួលហ្នឹងណាស ។

ដានី ៈ ហួស! សាលាប្រាយវេតហ្នឹ?

ជន ៈ អត់ទេ នៅកុលបុត្រនិយម ។

ដានី ៈ ហើយអ៊ីមករៀននៅភ្នំពេញឆ្នាំណាទៅ?

ជន ៈ មិនដឹងជាឆ្នាំណាទេនាក អាដែលខ្ញុំចេញទៅភ្នំពេញទៅឆ្នាំ១៩៦២ ។

ដានី ៈ អ៊ីរៀននៅភ្នំពេញបានប៉ុន្មានឆ្នាំ?

ជន ៈ ខ្ញុំរៀនបានបីឆ្នាំ ។

ដានី ៈ បីឆ្នាំ ។ កាលរៀននៅភ្នំពេញរៀននៅសាលាណា?

ជន ៈ រៀននៅសាលាព្រះយុគន្ធរដល់ក្រោយមក បងខ្ញុំគាត់សុំឲ្យមករៀននៅសាលាកុលបុត្រនិយម ហួស! រួចហើយបានមកនៅសាលាព្រះយុគន្ធរ គាត់ស្គាល់គេ គាត់បានឲ្យខ្ញុំចូលនៅហ្នឹងបានពីរឆ្នាំ ។

ដានី ៈ អ៊ីចឹងកាលអ៊ីរៀននៅកំពង់សំបួរ អ៊ីរៀនបានថ្នាក់ទី៦ ដល់ថ្នាក់ទីទី៦អ៊ីផ្លាស់មកនៅសាលាកុលបុត្រនិយម ។

ជន ៈ ដល់ថ្នាក់ទី៥ ។

ដានី ៈ រៀនថ្នាក់ទី៥?

ជន ៈ បាទ! ទី៥ដល់ពេលខ្ញុំចូលទៅសាលាព្រះយុគន្ធរថ្នាក់ទី៤ ដល់ទី៣ខ្ញុំអត់បានប្រឡងទេ ដល់ថ្នាក់ទីបីនេះខ្ញុំចេញមកម៉ង ។

ដានី ៈ ហួស! អ៊ីចឹងអ៊ីនៅរៀននៅយុគន្ធរហ្នឹងថ្នាក់ទីបីឆ្នាំ១៩៦២?

ជន ៈ បាទ ។

ដានី ៈ ចុះអ៊ីស្គាល់ ម៉ែន ជន ដែរអត់?

ជន ៈ ទេ! ដូចមិនស្គាល់ទេ ។

ដានី ៈ ចុះ ហ៊ឹង ស្គាល់ ហ៊ឹង ទេ?

ជន ៈ ហ៊ឹង?

ដានី ៈ ហ៊ឹង គណៈតំបន់ប្រាំ ។

ជន ៈ ទេ តា ហ៊ឹង ខ្ញុំតាមមើលដូចអត់ស្គាល់ទេ តែខ្ញុំដឹងដែរ ដឹងថាគាត់នៅរៀនហ្នឹងដែរ ។

ដានី ៈ រៀនអីគេ?

ជន ៈ រៀន ដែលប្រជុំ ទៅប្រជុំអីម្តងៗណាស ដឹងតែប៉ុណ្ណឹងទេ ។

ដានី ៖ អីចឹងអ៊ីរៀននៅព្រះយុគន្ធរហ្នឹងដល់ឆ្នាំ៦២?

ជន ៖ បាទ! ឆ្នាំ៦២ ថ្នាក់ទី៤ ។

ដានី ៖ ថ្នាក់ទី៤ បានចូលរៀនថ្នាក់ទី៣ទេ?

ជន ៖ អត់!

ដានី ៖ អត់ទេ?

ជន ៖ បាទ!អត់ទេ ។

ដានី ៖ កាលនោះរៀនប្អូនអ៊ីជាអ្នកផ្គត់ផ្គង់?

ជន ៖ បាទ!ប្អូនស្រី គ្នាស៊ីឈ្នួលគេ ផ្គត់ផ្គង់ឲ្យរៀន ។

ដានី ៖ ស៊ីឈ្នួលគេផ្គត់ផ្គង់អ៊ីឲ្យរៀន ស៊ីឈ្នួលខាងអីគេទៅ?

ជន ៖ គាត់រស់នៅដូចថានៅជាមួយចិនអីចឹង ដាំបាយ ឬក៏យើងបោកខោអាវឲ្យគេណាស ។

ដានី ៖ កាលនោះប្អូនអ៊ីអាយុប៉ុន្មានទៅស៊ីឈ្នួលគេ?

ជន ៖ កាលនោះអាយុ ១៦ ១៧ហ្នឹងហើយ ហើយខ្ញុំអាយុប្រហែលជា២០ហើយ ។

ដានី ៖ អីចឹងប្អូនអ៊ីស៊ីឈ្នួលហ្នឹងយកលុយឲ្យអ៊ីរៀន?

ជន ៖ បាទ!ដល់ខ្ញុំរៀនទៅនឹកឃើញថាប្អូនផ្តល់ឲ្យវាមិនទាន់ ហើយម្យ៉ាងយើងក៏ពិបាកដូចថាគិតកន្លល់ពេកឪពុកក៏មិនមាន ម្តាយក៏មិនមាន ហើយនៅតែបងប្អូនពីរនាក់ ខ្ញុំក៏សំរេចចិត្តថាអីចឹងទៅ ។ ថាមកប៉ៃលិននេះថាចូលធ្វើអា រកស៊ីជីកត្បូង ។

ដានី ៖ ចុះអ៊ីកាលនៅភ្នំពេញអ៊ីស្នាក់នៅឯណាទៅ?

ជន ៖ ភ្នំពេញខ្ញុំនៅវត្តលង្ការ ។

ដានី ៖ នៅវត្តលង្ការ?

ជន ៖ បាទ!

ដានី ៖ ចុះប្អូន?

ជន ៖ ប្អូនខ្ញុំនៅផ្ទះចិន ។

ដានី ៖ ហ្អស!អីចឹងអ៊ីនៅស្នាក់នៅរៀនហ្នឹងនៅវត្តលង្ការ?

ជន ៖ នៅវត្តលង្ការ ។

ដានី ៖ នៅវត្តនៅកុដមួយណា?

ជន ៖ នៅ...អាចារ្យឆិ នៅខាងត្បូងព្រះវិហាហ្នឹង ។

ដានី ៖ ម៉េចបានអ៊ីស្គាល់អាចារ្យ ឆិ ហ្នឹងហើយបានទៅស្នាក់នៅវត្តហ្នឹង?

ជន ៖ បាទ!បងប្អូនខ្ញុំហ្នឹងដូចថាគាត់បួស គាត់អាចារ្យដែរ ហើយគាត់មកនៅហ្នឹង គាត់ហៅខ្ញុំមកនៅហ្នឹងជួយដើរបានទៅបិណ្ឌបាតបិនអី ខ្ញុំទៅដាក់បាតដាក់អីយកចានស្រាក់ដាក់ឲ្យគាត់ទៅ ។

ដានី ៖ ឈ្មោះអីបងប្អូនអ៊ីដែលបួសដែរនោះ?

ជន ៖ អាចារ្យ ជី ។

ដានី ៖ អាចារ្យ ជី?

ជន ៖ បាទ!

ដានី ៖ ចុះកាលអ៊ីរៀននៅកុលបុត្រនិយម នៅព្រះយុគន្ធរមានស្គាល់គ្រូណាទេ?

ជន ៖ មិនដឹងគ្រូណាគ្រូទេខ្ញុំអត់សូវចាំទេ សូម្បីតែកុលបុត្រនិយមហ្នឹងក៏ខ្ញុំ... គេហៅថាកាលនោះចាំតែដល់ឥឡូវអត់ចាំទេ ។

ដានី ៖ ចុះព្រះយុគន្ធរ?

ជន ៖ ព្រះយុគន្ធរក៏អត់ចាំដែរ ។

ដានី ៖ អត់មានចាំលោកគ្រូណាម្នាក់ដែលគាត់ល្បីអីអត់មានចាំទេ?

ជន ៖ អត់មានទេ ។ កាលនោះអត់មាននឹកនាអីទេ គិតតែរឿងរៀនទេ ។

ដានី ៖ អីចឹងអ៊ីបន្ទាប់ពីឈប់រៀនឆ្នាំ៦២មកអ៊ីចេញមកខាងបាត់ដំបងឬមកប៉ៃលិន?

ជន ៖ មកបាត់ដំបង ។

ដានី ៖ មកបាត់ដំបង?

ជន ៖ មកបាត់ដំបងហើយស៊ីឈ្នួលចិនតែម្តង ។

ដានី ៖ មូលហេតុអីដូចជាឆ្នាំ៦២ហ្នឹងអ៊ីដូចថាចេញមកស៊ីឈ្នួលគេនៅបាត់ដំបងអត់នៅភ្នំពេញអីចឹង?

ជន ៖ ពេលនោះខ្ញុំអត់សូវដឹងដែរ រកមុខរបបអីមិនឃើញ ចេញមកថាចេញឲ្យផុតមកបាត់ដំបងដើម្បីមករកជីកត្បូងទេតើ មានមិត្តភ័ក្តគេហៅមកថាមករកជីកត្បូង ។ ដល់មកមិនទាន់ដល់គោលដៅសំរេចផងក៏ជាប់អាចិនហ្នឹងទៅក៏ចូលហ្នឹងទៅដើម្បីយកទុនទៅទៀត ។

ដានី ៖ អីចឹងអ៊ីថាមកស៊ីឈ្នួលចិនហ្នឹង ចិននៅឯណា ហើយរកស៊ីអីដែរ?

ជន ៖ បាទ!គាត់នៅដំណាក់ស្តៅ ។

ដានី ៖ គាត់រកស៊ីអីចិនហ្នឹង?

ជន ៖ គាត់រកស៊ីលក់ចាប់ហួយ គាត់មានចំការនៅអាដែងភ្នំហ្នឹងដែរ ។

ដានី ៖ ភ្នំអីដែរ?

ជន ៖ អាភ្នំនៅជិតដំណាក់ស្តៅហ្នឹងមិនដឹងហៅភ្នំអីដែរ ។

ដានី ៖ ស្រុករតនមណ្ឌលហ្នឹង?

ជន ៖ បាទៗ!

ដានី ៖ អីចឹងកាលនោះអ៊ំស៊ីញ្ញុលខាងអីទៅគាត់លក់ចាប់ហួយអីចឹង?

ជន ៖ កាលនោះគេឲ្យចូលទៅចំការ ដល់ចូលទៅចំការអីចឹងទៅគេមានពិសោធន៍មួយ គេឲ្យខ្ញុំ ដល់ម៉ោងគេទៅជញ្ជូនចេកជញ្ជូនក្រូចអីយកមកដាក់ឡានគេ ដល់អីចឹងគេហៅមកផ្ទះៗ ដល់ហៅមកផ្ទះអីចឹងខ្ញុំគេឲ្យដេកនៅសំយ៉ាបអីចេះ សំយ៉ាបផ្ទះគេមានគ្រែធំដែរ ល្មមតែដេកចង់មុងអីបានគេឲ្យខ្ញុំនៅអីចឹងទៅ ហើយខ្ញុំគិតថាអញមកស៊ីញ្ញុលគេ ណ្ហើយចុះ!គិតថាងើបពីយប់ជូតអានេះចុះផ្ទះគេនោះណាស ជូតផ្ទះ បោសសំរាមស្អាតបាតអស់ហើយចឹងទៅក៏ដងទឹកដាក់ពាងឲ្យគេៗគេមិនបានប្រើបានអីទេ តែយើងចេះតែធ្វើទៅ ដល់ព្រឹកឡើងម្ចាស់គេចេញមកគេឃើញចឹងស្អាតទៅផ្ទះគេ មិនដឹងជាគេនិយាយជាមួយប្តីគេយ៉ាងម៉េចទេ គ្រាន់តែគេថា ទុកម្នាក់ហ្នឹងនៅហ្នឹងហើយ ៗ

ដានី ៖ ចិនហ្នឹងឈ្មោះអីទៅដែលអ៊ំស៊ីញ្ញុលជាមួយនោះ?

ជន ៖ ឈ្មោះ...ភ្លេចបាត់ហើយ....ចឹក ហៀងបាទ!

ដានី ៖ អ៊ំស៊ីញ្ញុលហ្នឹងពីឆ្នាំដល់ឆ្នាំណាដែរ?

ជន ៖ ខ្ញុំបានតែប៉ុន្មានខែទេ តែមិនដឹងឆ្នាំណាទេ តែខ្ញុំដឹងតែចេញមកច្រើន ឆ្នាំ១៩៦២បាទៗ

ដានី ៖ អីចឹងពេលអ៊ំស៊ីញ្ញុលហ្នឹងស៊ីបានតែប៉ុន្មានខែទេ?

ជន ៖ បានប្រហែលពីរបីខែដែរហ្នឹងណាសបានខ្ញុំចូលមកក្នុងទៀត ចូលមកខាងដំណាក់ស្មៅទៀតៗ

ដានី ៖ កាលអ៊ំថាស៊ីញ្ញុលចិនហើយអ៊ំបង្រៀនកូនចិនទៀតភាសាខ្មែរ ភាសាបារាំង?

ជន ៖ បាទៗ

ដានី ៖ បង្រៀននៅឯណាដែរ?

ជន ៖ បង្រៀននៅហ្នឹងផ្ទះហ្នឹងៗ

ដានី ៖ ចឹក ហៀង ហ្នឹង?

ជន ៖ បាទ!ចឹក ហៀង ហ្នឹងៗ

ដានី ៖ បង្រៀនយ៉ាងម៉េចទៅកូនហ្នឹង?

ជន ៖ បង្រៀន អ៊ី អ៊ុយ ចឹងទៅ ចេះតែបង្រៀនទៅណាស ហើយខ្មែរយើងបង្រៀនតែ ក ខ ស្រះអីចឹងទៅៗ

ដានី ៖ បង្រៀនកូនចិនប៉ុន្មាននាក់ដែរ?

ជន ៖ ពីរបីបួនប្រាំនាក់អីចឹងទៅ តែដូចយើងបង្រៀនមួយសន្ទុះៗចឹងទៅណាសពេលទំនេរអីៗ

ដានី ៖ បង្រៀនប្រហែលរយៈពេលប៉ុន្មានដែរ?

ជន ៖ ពីរបីខែដែរ ។

ដានី ៖ ដល់បគ្រៀនហើយយ៉ាងម៉េចទៀត?

ជន ៖ ចេញពីហ្នឹងទៀតទៅ ។

ដានី ៖ ចេញពីផ្ទះ ចឹក ហឿង មកនៅឯណាទៀតទៅ?

ជន ៖ ចេញពីហ្នឹងទៀតទៅមកនៅយើង រស្មីសន្លា ។

ដានី ៖ នៅឯណារស្មីសន្លាហ្នឹង?

ជន ៖ បាទ!រស្មីសន្លាមកឯជើងអណ្ដើកហេតុទៀត អាផ្លូវជើងមួយមកខាងគិរីជុំ ភ្នំបាំងដាកអីណាស ។

ដានី ៖ នៅឯណាទៅអាហ្នឹង គីរីជុំ ភ្នំបាំងដាក?

ជន ៖ នៅបាត់ដំបង ។

ដានី ៖ នៅបាត់ដំបងម្ដុំណា គេហៅអីអាហ្នឹង ស្រុកអីគេ?

ជន ៖ ហ្នឹងហើយស្រុករតនៈមណ្ឌល ។

ដានី ៖ ស្រុករតនៈមណ្ឌល កន្លែងស្ពោកន្លែងគ្រែង?

ជន ៖ បាទៗ គ្រែងវានៅលិចអីចេះតែខ្ញុំទៅខាងជើងវិញ ។

ដានី ៖ អត់ចូលទៅខាងសេកសកសេកអីទេ?

ជន ៖ អត់ទេ ។

ដានី ៖ ហើយអ៊ំទៅស៊ីឈ្នួលនៅកន្លែងរស្មីសន្លាហ្នឹងស៊ីឈ្នួលធ្វើអី រយៈពេលបានប៉ុន្មានដែរ?

ជន ៖ ធ្វើចំការដកស្មៅចាំងស្មៅឲ្យគេ ។

ដានី ៖ ចំការអីគេ?

ជន ៖ ចំការចេក ពោត សណ្ដែក ហើយចំការដូចដាំផ្លែក្រូច ខ្នុរអីហ្នឹង ដូងអី ចេកអីហ្នឹង ។

ដានី ៖ កាលនោះអ៊ំស៊ីឈ្នួលតែម្នាក់ឯងឬក៏មានគេផ្សេងទៀត?

ជន ៖ ហួស!ច្រើនមិនមែនតែម្នាក់ឯងទេ តែខ្ញុំទៅប្រឡូកជាមួយគេណាស ។

ដានី ៖ ឈ្នួលបានរយៈពេលប៉ុន្មានដែរ?

ជន ៖ ទេ!រហូតទាល់តែបានគ្រួសារ ។

ដានី ៖ ដល់ឆ្នាំណាដែលអ៊ំបានគ្រួសារ?

ជន ៖ គ្រួសារឆ្នាំ១៩៧០ ។

ដានី ៖ ៧០ ពេលរដ្ឋប្រហារហើយឬអត់ទេ?

ជន ៖ ដូចមិនដឹងថារដ្ឋប្រហារហើយឬនៅទេ បានប្រពន្ធឆ្នាំ៧០ហ្នឹងដល់៧១បានខ្ញុំរត់ចេញពីហ្នឹងទៀត អាហ្នឹងកំពុងតែវៃខ្លាំងហើយ ។

ដានី ៖ អ៊ឹមានចាំខែទេដែលការប្រពន្ធឆ្នាំ៧០ហ្នឹង?

ជន ៖ ទេ!ដូចជាអត់ចាំខែទៀតហ្នឹង ។

ដានី ៖ ព្រោះរដ្ឋប្រហារទម្លាក់សម្តេចនៅថ្ងៃទី១៨ ខែ៣ ឆ្នាំ១៩៧០ ។

ជន ៖ ព្រោះអា៧០ហ្នឹងខ្ញុំបានហើយ បានប្រពន្ធហើយណាស ។

ដានី ៖ ចុះប្រពន្ធអ៊ីហ្នឹងកូនរបស់ម្ចាស់ហាងរស្មីសន្ធាហ្នឹង?

ជន ៖ អត់ទេ គាត់ផ្សេងទេ ។ គាត់ដូចថាបងប្អូនគាត់ដែលមកធ្វើចំការហ្នឹង គាត់ជាថៅកែណាស ហើយគាត់ក្មួយថៅកែហ្នឹង ។

ដានី ៖ ហ្អស!ប្រពន្ធអ៊ីក្មួយថៅកែហ្នឹង?

ជន ៖ បាទ!

ដានី ៖ គាត់ឈ្មោះអីទៅ?

ជន ៖ ថៅកែហ្នឹង?

ដានី ៖ អត់ទេ ប្រពន្ធអ៊ី ។

ជន ៖ គាត់ឈ្មោះ ដួន រិន ។

ដានី ៖ ដួន រិន ហ្នឹងប្រពន្ធអ៊ី?

ជន ៖ បាទ!

ដានី ៖ ចុះប្រពន្ធអ៊ីអ្នកស្រុកនៅឯណា?

ជន ៖ នៅបាក់ព្រា ហ្នឹងកមណើតគាត់ណាស នៅបាក់ព្រាហ្នឹងឯង តែស្រុកកំណើតខាងម្តាយគាត់នៅ ឱម៉ាល់យើងបត់ត្រង់ ។

ដានី ៖ អ៊ីចឹងពេលអ៊ឹមកជួបប្រពន្ធពេលមកធ្វើការជាមួយគ្នានៅរស្មីសន្ធាហ្នឹង?

ជន ៖ បាទ!

ដានី ៖ អ៊ឹស្រលាញ់គ្នាឬយ៉ាងម៉េច?

ជន ៖ បាទ!ស្រលាញ់គ្នាដែរហ្នឹងណាស...ស៊ើច ។

ដានី ៖ ស្រលាញ់គ្នាទៅបានការ?

ជន ៖ បាទ!

ដានី ៖ ការត្រឹមត្រូវ?

ជន ៖ បាទ!ការត្រឹមត្រូវ តែកាលនោះការមិនអស់ប្រាក់អីច្រើនដូចយើងឥឡូវទេណាស ការអស់តែ មួយពាន់ពីរពាន់អីហ្នឹង ។

ដានី ៖ បាទ!ដល់អ៊ឹការហើយ បងប្អូនខាងអ៊ឹអីមកចូលរួមការដែរអត់?

ជន ៖ អត់ទេ! តែម្នាក់ឯងគត់ តែប្អូនស្រីក៏គាត់នៅភ្នំពេញទេ ។

ដានី ៖ អត់ដឹងទេ?

ជន ៖ បាទ! ដឹងតែខ្ញុំនិងគ្រួសារខ្ញុំទេ ហ្នឹងខាងស្រីគេដឹងណាស បើខ្ញុំមានតែម្នាក់ឯងទេ ។

ដានី ៖ ចុះពេលអឺការហើយយ៉ាងម៉េចទៀតទៅអ៊ី?

ជន ៖ ដល់ការហើយ ទៅខ្ញុំចាប់អាទីតាំងសុំគាត់ចេញមកដាំបន្លែដាំអីលក់ទៅ ដាំបន្លែស្ពៃ ។

ដានី ៖ អឹសុំគាត់ចេញមកនៅឯណាវិញ?

ជន ៖ ចេញមកសុំដីគេធ្វើ អាកន្លែងគេមានទឹកណាស ។

ដានី ៖ នៅឯណាទៅ?

ជន ៖ មកនៅខាង ឧទាហរណ៍ដូចខ្ញុំនៅឃុំនេះចឹង នៅឃុំទឹកពុះ មកខាងទឹកពុះវិញ មកដាំបន្លែនៅទឹកពុះ ។

ដានី ៖ ទឹកពុះនៅឯណាដែរ?

ជន ៖ ទឹកពុះនៅក្បែរគ្នាដែរ ក្បែររស្មីសន្លាដែរ ។

ដានី ៖ ក្បែររស្មីសន្លានៅស្រុករតនៈមណ្ឌលដែរ?

ជន ៖ បាទ! ប្រហែលជាប្អូនប្រាំម៉ែត្រអីដឹងចុះពីនោះមក ។

ដានី ៖ អឹដាំបន្លែហ្នឹងយ៉ាងម៉េច?

ជន ៖ តែពីរនាក់ប្តីប្រពន្ធទេហើយអត់មានលុយទេ កាលនោះវាក្រហួស ប្រមាណដែរខ្ញុំសុំគ្រាប់ស្ពៃគេចឹងទៅ គេឲ្យមួយកញ្ចប់ស្ពៃដើងទាមួយកញ្ចប់ ខាត់ណា ស្ពៃក្តោប អីចឹងទៅគេចាក់ឲ្យតិចៗចឹងទៅខ្ញុំយកទៅដាំ ។ ដល់ដាំទៅយើងប្រកបចឹងទៅវាកាក់កបដែរ ។

ដានី ៖ អឹដាំបានរយៈពេលប៉ុន្មានឆ្នាំដែរ ដាំបន្លែ?

ជន ៖ បាន មួយឆ្នាំជាងហើយមានទុនគ្រាន់បើហើយ ។

ដានី ៖ ចុះដល់ពេលដាំហើយធ្វើអីទៀតទៅ?

ជន ៖ ដល់ពេលដាំហើយដូចខ្ញុំថាអីចឹង វាមានពួកខ្មែរក្រហមពួកព្រៃអីចឹងណាសវាមកចាត់តាំងខ្ញុំឲ្យទៅខាងសេដ្ឋកិច្ច ដល់អ្នកខាងក្នុងគេឲ្យខ្ញុំធ្វើខាងមេ៥០ខ្ទង់ ដល់ខ្ញុំឃើញពីរនាក់វាប្រឆាំងគ្នាអីចឹងខ្ញុំក៏ឈប់លះបង់ដាំអាហ្នឹងឡើងមករកបងប្អូនខាងប្រពន្ធខ្ញុំនៅឪម៉ាល់ផ្លូវកាត់វិញណាស ។ ដល់មកដល់អីណោះគេថាគេចូលអីណោះបាត់ទៀតហើយ អីចឹងខ្ញុំក៏ថាបើគេចូលហើយចូលនឹងគេដែរទៅ ។

ដានី ៖ ពេលអឹកាលពេលអឹមកដាំបន្លែបានមួយខែជាងមិញហ្នឹង អឹមានប្រសាសន៍ថាខ្មែរក្រហមគេឡើងមកចាត់តាំងខាងសេដ្ឋកិច្ចអីចឹងហ្អី?

ផន : បាទ! ខាងសេដ្ឋកិច្ច ។

ដានី : ចុះខ្មែរក្រហមកាលនោះអឺការឆ្នាំ៧០ ហើយនៅដាំបន្លែប្រហែលមួយឆ្នាំទៀតប្រហែល៧១ ឬ ៧២?

ផន : ប្រហែល៧១ទេដឹង ។

ដានី : អីចឹងខ្មែរក្រហមកាលនោះមកពីណាដែរមកចាត់តាំងអ៊ឹ?

ផន : ទេ! ថាមកពីវាលចារពីណាមកទេ ខ្ញុំមិនសូវដឹងទេ ហើយដល់គេមកអីចឹងគេឃើញខ្ញុំដាំបន្លែចឹង គេរៀបចំឲ្យខ្ញុំកាន់ខាងសេដ្ឋកិច្ចតែម្តង ។

ដានី : សេដ្ឋកិច្ចហ្នឹងបានន័យថាសេដ្ឋកិច្ចរបស់អីគេ?

ផន : អាសេដ្ឋកិច្ចរបស់គេដូចថាតែត្រូវការបន្លែចឹងខ្ញុំជូនបន្លែគេទៅ ។

ដានី : យើងជូនបន្លែហ្នឹងសំរាប់កងគេឬគេចាត់ទុកថាសេដ្ឋកិច្ចរបស់ភូមិរបស់ស្រុក?

ផន : មិនដឹងរបស់អីទេ អានេះគេគ្រាន់តែ ដូចថាចំពោះក្រុមគេអីចឹងណាស ។

ដានី : បាទ! អ៊ឹមានចាំឈ្មោះខ្មែរក្រហមដែលមកពីវាលចាមហ្នឹង?

ផន : ហ្អស! អត់ដឹងទេ ។

ដានី : មានស្គាល់មេគេថាមកពីណាដែរទេ?

ផន : អត់មានដឹងថាមេគេយ៉ាងម៉េចផង គ្រាន់តែគេចាត់តាំងបានប៉ុន្មានថ្ងៃ មើលតែសភាពការណ៍ មិនល្អខ្ញុំ ប្រុច ។

ដានី : ភ្នំវាលចាមនៅឯណាទៅ?

ផន : ភ្នំវាលចាមហ្នឹងនៅខាងអណ្តើកហែមនេះ ដំណាក់ស្តៅនេះ នៅខាងត្បូងដំណាក់ស្តៅនេះ ។

ដានី : ខាងត្បូងនៅជិតដែរឬយ៉ាងម៉េច?

ផន : ទេ! មិនដឹងជិតឬឆ្ងាយទេ ខ្ញុំមិនសូវដឹងដែរដឹងតែនៅភ្នំវាលចាមនេះឯង តែមិនដឹងពិតឬមិនពិត ណាស ។

ដានី : ចុះខាង លន់ នល់ គេមកចាត់តាំងឲ្យអ៊ឹទៅធ្វើមេ៥០ខ្នងហ្នឹងគេមកចាត់តាំងអ៊ឹពីអង្កាល់?

ផន : បាទ! អាហ្នឹងក្រោយ ខ្មែរក្រហមគេចាត់តាំងហើយបានខាងណោះគេរៀបផែនការហ្នឹងគេចាត់តាំងខ្ញុំដែរឲ្យខ្ញុំទទួលខុសត្រូវនៅផ្ទះប៉ុន្មានខ្នងហ្នឹងណាស ឲ្យខ្ញុំធ្វើមេ៥០ខ្នង ។

ដានី : មេ៥០ខ្នងហ្នឹងប្រហែលប្រធានភូមិអីហ្អី?

ផន : បាទ! ប្រហែលប្រធានភូមិអីហើយខ្ញុំមិនសូវដឹងដែរ ។

ដានី : លន់ នល់ ដែលមកចាត់តាំងហ្នឹង លន់ នល់ នៅខាងណាដែរ?

ផន : អត់ទេ អាហ្នឹងដូចថាពួកគេនៅបាត់ដំបង តែមិនដឹងនៅភូមិអីដែរទេ គាត់មកដល់គាត់ថា ឥឡូវអត់មានអ្នកណាទេ មានតែប្អូនឯងហ្នឹងហើយដូចថាមានសមត្ថភាពណាស គេរៀបចំខ្ញុំអីចឹងខ្ញុំថាអត់ទេ អត់ទាន់ហានទទួលទេដូចថាមនុស្សខ្ញុំក្រខ្សត់អីចឹងធ្វើអីចឹងម៉េចសម ។ អានេះយើងចេះតែនិយាយដើម្បីដោះខ្លួនណាស ពេលនោះអត់បានធ្វើទេ គ្រាន់តែចាត់តាំង ខ្ញុំអត់បានធ្វើទេ ។

ដានី : បានរយៈពេលប៉ុន្មានទៅបានអ៊ំ ដូចអ៊ំមានប្រសាសន៍ថារត់មកខាងប្រពន្ធអ៊ំមនៅខាងឪម៉ាល់បត់ត្រង់វិញ?

ផន : ចំនួនបីខែ ។

ដានី : បីខែ?

ផន : បាទ ។

ដានី : កាលនោះអ៊ំមានកូនហើយនៅ?

ផន : មានកូនមួយ អាកូនស្រីនោះ ។

ដានី : កូនស្រីមួយ?

ផន : បាទ!កូនស្រីហ្នឹងបានប្រាំ ពីរបីខែដែរហ្នឹងបានកូនស្រីហ្នឹងគាត់ស្លាប់ទៅ ។ ដល់ស្លាប់ទៅបានក្រោយមកទៀតបានកូនប្រុស ។ កូនប្រុសក៏នៅហ្នឹងដែរ ។

ដានី : នៅឯណា?

ផន : នៅកន្លែងហ្នឹងដែរ នៅភូមិហ្នឹងដែរ រស្មីសង្ហាហ្នឹង ។

ដានី : នៅរស្មីសង្ហាបានកូនប្រុសមួយទៀត?

ផន : បាទ! កូនប្រុសមួយទៀត ។

ដានី : កើតហើយ?

ផន : កើតហើយបានរដ្ឋហ្នឹងបណ្តោយ ។

ដានី : បានប៉ុន្មាន? អាយុប៉ុន្មាន?

ផន : ប៉ុន្មានខែទេ នៅបីរត់ហ្នឹងណាស ។

ដានី : រត់មកខាងឪម៉ាល់ហ្នឹងវិញ?

ផន : បាទ!មកឪម៉ាល់ផ្លូវកាត់វិញ ។

ដានី : ឆ្ងាយទេ រត់ពីរស្មីសង្ហាមក?

ផន : ហ្អាក!ឆ្ងាយ ចុះបើអាមួយនៅផ្លូវទឹកអាមួយនៅផ្លូវគោក ចុះតាមស្ទឹងក្រោម ចុះទៅបាក់ព្រាហើយពីបាក់ព្រាមកឪម៉ាល់ផ្លូវកាត់ ហើយបើយើងនៅតាមដងស្ទឹងឆ្ងាយ ឆ្ងាយមែនទែន មកដល់ពាមសេមាំបានចាក់ឡើងមកលើនេះវិញ ។

ដានី ៖ ឆ្ងាយណាស់អីចឹង?

ផន ៖ បាទ!ឆ្ងាយណាស់ បើយើងទៅផ្លូវឡានក៏ឆ្ងាយ ផ្លូវឡានពីបាត់ដំបងមកឡើងឆ្ងាយតាមផ្លូវជាតិលេខ៦ ។

ដានី ៖ ឪម៉ាល់ហ្នឹងនៅស្រុកអីគេ?

ផន ៖ បាទ!នៅស្រុកព្រះនេត្រព្រះ ។

ដានី ៖ ឪម៉ាល់ហ្នឹងខាងស្រុកព្រះនេត្រព្រះវិញ?

ផន ៖ បាទ!

ដានី ៖ ខាងបត់ត្រង់ព្រះនេត្រព្រះ?

ផន ៖ បាទ! បើត្រើយខាងកើតខាងកើតទៅខាងសៀមរាប ស្រុកស្ទឹស្នំទេបង?

ដានី ៖ ស្រីស្នំ?

ផន ៖ ស្រីស្នំទេដឹង1 ខាងកើត មិនដឹងស្រុកអីខ្ញុំអត់សូវស្គាល់ដែរ ។

ដានី ៖ អីចឹងមកខាងឪម៉ាល់ បត់ត្រង់ហ្នឹងមកខាងហ្នឹងក្នុងស្រុកព្រះនេត្រព្រះនេះទេ?

ផន ៖ បាទ!ព្រះនេត្រព្រះ ម៉ាចំហៀងព្រះនេត្រព្រះ ម៉ាចំហៀងសៀមរាប ។

ដានី ៖ កាលនោះដែលអឹរត់មក ទាំងប្រពន្ធទាំងកូនរត់មកអស់គ្នា?

ផន ៖ បាទ!ទាំងអស់គ្នា ។

ដានី ៖ ពេលមកដល់ខាងស្រុកកំណើតខាងប្រពន្ធនៅខាងឪម៉ាល់ហ្នឹងយ៉ាងម៉េច? គេចូលខ្មែរក្រហមអស់?

ផន ៖ គេចូលខ្មែរក្រហមអស់រលីង ។

ដានី ៖ ចូលព្រៃនៅឯណាទៅ?

ផន ៖ ចូលព្រៃហ្នឹង អាព្រៃយើងរនាមហ្នឹង ។

ដានី ៖ ព្រៃរនាមហ្នឹង?

ផន ៖ បាទ!ដល់មកគេចូលចឹង ខ្ញុំក៏ចូលហ្នឹងគេ ចុះយើងមិនដឹងនៅឯណា បើយើងពីមុនថាមកនៅភូមិដល់គេថាទៅនៅក្នុងព្រៃចឹងទៅ ខ្ញុំក៏សំរេចថាទៅនៅក្នុងព្រៃទៅមិនដឹងទៅណា ។

ដានី ៖ ឆ្នាំណាហ្នឹងអឹដែលមកដល់ហ្នឹង?

ផន ៖ ឆ្នាំ៧១ ។

ដានី ៖ ៧១ដដែលទេ?

ផន ៖ បាទ!៧១ ៧១ ជិតចូល៧២ហើយ ។

ដានី ៖ ដូចអ៊ីចូលក្នុងព្រៃអីចឹង ដូចអ្នកស្រុកភូមិដែលគេចូលក្នុងព្រៃហ្នឹងពីណាគេអ្នកដឹកនាំអ៊ី មានចាំអ្នកដឹកនាំនៅក្នុងព្រៃដែរទេ?

ផន ៖ អាហ្នឹងដូចឃើញខាងសៀមរាប ។

ដានី ៖ ខាងសៀមរាប?

ផន ៖ បាទ! តែមិនដឹងឈ្មោះអីទេ ខ្ញុំអត់សូវស្គាល់ទេ អាហ្នឹងគេនាំចូលណាស គេទំនាក់ទំនងគ្នាយ៉ាងម៉េចទេខ្ញុំអត់ដឹងដែរ ។

ដានី ៖ អ៊ឹអត់ដែលព័ឈ្មោះដូចថាខាងនេះខាងនោះមេគេអីចឹងទេឈ្មោះអីៗ?

ផន ៖ អត់ទេៗ ។

ដានី ៖ ដែលឮទេ?

ផន ៖ អត់ដែលដឹងផង តែដឹងថាអ្នកដឹកនាំនោះខាងសៀមរាប ។

ដានី ៖ ខាងសៀមរាប? ខាងសៀមរាបហ្នឹងតំបន់ផ្សេងគ្នា?

ផន ៖ បាទ! តំបន់ផ្សេងគ្នា តែយើងមិនទាន់ដឹងថារៀបជាតំបន់យ៉ាងម៉េចយ៉ាងម៉ាខ្ញុំមិនសូវដឹងទេ គ្រាន់តែថាពួកនោះគេចុះពីលើមកគេយកពីខាងសៀមរាបមកដើម្បីរៀបចំកម្លាំងហ្នឹង ដូចថាប្រជាជនចូលប៉ុន្មានអីប៉ុន្មានចឹងទៅ ។

ដានី ៖ កាលនោះអត់ដែលឃើញ តា ហ៊ីង តាអីចូលទៅខាងនោះទេ?

ផន ៖ អាហ្នឹងយើងនេះហើយ អត់អីទេ អាហ្នឹងគាត់ផ្សេងទេ ក្រោយមកទៀតទេ ។

ដានី ៖ ក្រោយទេ ចឹងកាលតស៊ូហ្នឹងអត់ទេ?

ផន ៖ អត់ទេ នោះផ្សេង ។

ដានី ៖ តា ហ៊ីង តា សំអាត តា ម៉ោង តាអីអត់ទេ?

ផន ៖ តា ម៉ោង ហ្នឹងក្រោយទេ ។

ដានី ៖ ចុះអ៊ីពេលដែលចូលព្រៃនៅខាងឱម៉ាល់ហើយហ្នឹង កាលនោះគេចាត់តាំងឲ្យអ៊ីអ្នករកម្ហូប?

ផន ៖ រកម្ហូប ។

ដានី ៖ ម៉េចបានគេចាត់តាំងឲ្យអ៊ីអ្នករកម្ហូបអីចឹង?

ផន ៖ គេឲ្យខ្ញុំ គេឲ្យរកសន្ទូចនោះផង រកឃ្មុំ អាដែងឃ្មុំយើងធំនោះណាស រកទឹកឃ្មុំឲ្យគេអាហ្នឹងដូចថាខាងសេដ្ឋកិច្ចណាស ។

ដានី ៖ កាលនោះអ្នកចាត់តាំងអ៊ីអ្នកណាគេចាត់តាំង?

ផន ៖ ពិបាកដែរ គាត់ស្លាប់បាត់ហើយហ្នឹងមិនដឹងឈ្មោះអីទៀតណាស ។ គាត់ហ្នឹងខាងទ័ពដែរ ។

ដានី ៖ គាត់ឈ្មោះអីទៅ?

ជន ៖ រកនឹកមិនឃើញទេ ។

ដានី ៖ គាត់ធ្វើទ័ពហ្អី?

ជន ៖ បាទ!ទ័ព ហើយគាត់អ្នកចាត់តាំងណាស ។

ដានី ៖ ដល់ពេលបែកគាត់មកនៅឯណាវិញ?

ជន ៖ ដល់បែក៧៥ហ្នឹងបែកគ្នាអស់ហើយអត់បានជួបគ្នាទៀតទេពួកហ្នឹង អាខ្លះគេចុះពីលើមក ចុះពីសៀមរាបមកគេក្តោបក្តាប់ ។

ដានី ៖ ចុះអ្នកបន្ទាប់ៗពីគាត់មក អ្នកដែលគស៊ូជាមួយអ៊ីហ្នឹងនៅខាងឱម៉ាល់ហ្នឹង មានចាំពីណាខ្លះ?

ជន ៖ អត់បានចាំទេ សុទ្ធតែងាប់អស់ហើយមិនដឹងអ្នកណាអ្នកណីទេ ។

ដានី ៖ ចុះអ៊ីនៅហ្នឹងបានរយៈពេលប៉ុន្មានដែរតាំងពីឆ្នាំ៧១ ៧២មករហូតដល់ពេលណាទៅ?

ជន ៖ ៧១, ៧២, ៧៣, ៧៣ក៏នៅក្នុងព្រៃនោះដែរ ។ ៧៤ ឡើងមកកៀនស្វាយ ។

ដានី ៖ ៧៤ឡើងមកនៅកៀនស្វាយ?

ជន ៖ បាទ ។

ដានី ៖ កៀនស្វាយមកឱម៉ាល់ជិតគ្នាដែរ?

ជន ៖ ដូចមិនជិតដែរ ឆ្ងាយដែរព្រោះវាកាត់តាមព្រៃមក ពីស្ទឹងមួយមកទល់ស្ទឹងមួយទៀត ។

ដានី ៖ កៀនស្វាយសំបួរហ្នឹងនៅជិតស្ទឹងកំបុតដែរហ្អី?

ជន ៖ បាទ! នៅជាប់គ្នាដែរហ្នឹងស្ទឹងកំបុត ។

ដានី ៖ ស្ទឹងកំបុត នៅក្នុងស្រុកមណ្ឌលបូរីហ្នឹងដែរហ្អី?

ជន ៖ បាទ! ស្រុកមណ្ឌលបូរី ។

ដានី ៖ មកជិតជាប់នឹងព្រះនេត្រព្រះហ្នឹងដែរ?

ជន ៖ ទេ ស្ទឹងកំបុតខុសហើយលោកគ្រូ មិនមែនទេ ស្ទឹងកំបុតនៅអីនេះអីណោះហ្នឹង ព្រះនេត្រព្រះអីនេះហ្នឹង ។

ដានី ៖ សំបួរហ្នឹងឆ្ងាយហ្អី?

ជន ៖ បាទ!ឆ្ងាយ ដងស្ទឹងមណ្ឌលបូរី ។

ដានី ៖ នៅដងស្ទឹងមណ្ឌលបូរី អីចឹងដល់៧៤មកនៅខាងកៀនស្វាយនេះវិញ?

ជន ៖ បាទ ។

ដានី ៖ មកធ្វើអីទៅ?

ជន ៖ គេឲ្យខ្ញុំរកម្ហូបរកអីដូចតាមធម្មតា ។

ដានី ៖ កាលនោះអ៊ីរកម្ហូបសំរាប់ផ្គត់ផ្គង់...?

ផន ៖ បាទ! សំរាប់ផ្គត់ផ្គង់ក្រុមខ្ញុំប្រហែល ១០ គ្រួសារ អីចឹងគេឲ្យខ្ញុំរកម្ហូបឲ្យគេហូបអីចឹងទៅណាស ហើយ គេតាមម្នាក់ៗ អីចឹងគេធ្វើការបំរើអង្គការ អីចឹងទៅ ។

ផានី ៖ គេធ្វើអីខ្លះទៅ?

ផន ៖ ដូចទៅដាំស្រូវឬយើងទៅច្រូតស្រូវឡើងមកខាងលើនេះវិញ ។

ផានី ៖ ដាំស្រូវ ច្រូតស្រូវអីចឹងទៅ?

ផន ៖ បាទ ។

ផានី ៖ អីចឹងអីតែម្នាក់ឯងទេអ្នករកម្ហូប?

ផន ៖ អត់ទេ បីបួននាក់ឯណោះចាស់ៗដូចគ្នា ។

ផានី ៖ រកម្ហូបបានឲ្យគេហូបរាល់ថ្ងៃដែរ?

ផន ៖ បាទ បានខ្លះអត់ខ្លះទៅ អាអត់ហ្នឹងយើងធ្វើម៉េចឲ្យបានជាស្លឹកផ្សេងៗទៀតទៅណាស ជាបន្លែ ជាអីចឹងទៅ ។

ផានី ៖ ចុះកាលនោះអីរកសំរាប់ផ្គត់ផ្គង់ ១០ គ្រួសារ អីចឹងហ្អី?

ផន ៖ បាទ!

ផានី ៖ ចុះក្នុង ១០ គ្រួសារហ្នឹងអ្នកណាអ្នកគ្រប់គ្រង?

ផន ៖ ទេ បើអត់ដឹងដែរ កាលនោះមិនទាន់មានចាត់តាំងអីត្រឹមត្រូវអីចឹងទេ គ្រាន់តែឲ្យខ្ញុំជាអ្នកបំរើគេ ១០ គ្រួសារហ្នឹងតែប៉ុណ្ណឹងឯង ។

ផានី ៖ មិនមែនគេចាត់តាំងអីធ្វើជាអ្នកដឹកនាំទេ?

ផន ៖ អត់ទេ ខ្ញុំអត់មានអ្នកដឹកនាំទេ ដូចថាខ្ញុំជាអ្នកធ្វើចឹងទៅណាស ។

ផានី ៖ ឆ្នាំ៧៨ហ្នឹងមកនៅហ្នឹងរកម្ហូបចឹងនៅឯណាទៀតទៅ?

ផន ៖ ដល់ឆ្នាំ៧៩ គេឲ្យខ្ញុំមើលគោ ដល់អាងៀចប់ហ្នឹងពួកនោះវាមកយកគោហ្នឹង ខ្ញុំស្មានតែខ្ញុំមានទោសទេតើ ដល់នេះទៅរួចទៅក៏គេប្រមូលឡើងមកវិញ ។

ផានី ៖ ចុះអីអាកាលឆ្នាំ៧៩ហ្នឹងមានគោពីណាមើលបើយើងនៅក្នុងព្រៃនោះ ។

ផន ៖ គោ មិនដឹងជាគេកៀពីណាមកទេ ដូចថាគេកៀងមកអីចឹងគេចាត់តាំងហើយណាស ដូចថាក្រុមនេះទៅមើលគោចឹងទៅ ចឹងចេះតែទៅហ្នឹងគេហើយអត់មានពិបាកទេ ឲ្យតែគេប្រើ ។

ផានី ៖ កាលនោះគោប៉ុន្មានទៅអឺ?

ផន ៖ គោច្រើនដែរហ្នឹងណាស ។

ផានី ៖ ប្រហែលប៉ុន្មានទៅ?

ផន ៖ ប្រហែល៥០, ៦០នឹម ។

ដានី ៖ ប្រហែល៥០, ៦០នឹម?

ផន ៖ បាទ មើលច្រើន។

ដានី ៖ មើលគ្នាប៉ុន្មាននាក់?

ផន ៖ ច្រើនណាស់ ម៉ាក្រុមហ្នឹងប្រហែលជា១៥នាក់ទៅដឹង ក្រុមមើលគោ។

ដានី ៖ ចុះអឹមានប្រសាសន៍អំបាញ់មិញថាមានតែ១០គ្រួសារ ដល់ពេលអឹដកគ្នា១៤, ១៥នាក់មកមើលគោ បានអ្នកណាទៅរកម្ហូបអីទៅ?

ផន ៖ អាហ្នឹងអត់ទេ ដល់ពេលដែលខ្ញុំមកណោះច្រើនណាស មកមើលគោនៅណោះណាស។

ដានី ៖ មើលគោនៅឯណា?

ផន ៖ មើលគោនៅហ្នឹងដែរ តែគេចែកម៉ាក្រុមគោអីចឹងទៅយើងនៅម៉ាផ្នែកគោណាស ហើយគ្រួសារ១០គ្រួសារ ខ្ញុំលែងអើពើហ្នឹងគេហើយខ្ញុំមកនេះវិញ ។

ដានី ៖ អីចឹងពេលគេចាត់មកមើលគោហ្នឹងមកមនុស្សច្រើនវិញហើយ ផុតចេញពី១០គ្រួសារហ្នឹងហើយ?

ផន ៖ បាទ ចេញមកទៀតហើយ ចេះតែទៅទៀតហើយ។

ដានី ៖ ចុះប្រពន្ធកូនអឹ?

ផន ៖ ព្រពន្ធកូនថ្ងៃណាសុំគេមកលេងក៏បានទៅ បើមិនបានក៏ធម្មតាទៅ។

ដានី ៖ ព្រពន្ធកូននៅឯណាទៅ?

ផន ៖ ប្រពន្ធកូននៅម៉ាក្រុមហ្នឹងទៅ ដូចថានៅម៉ាក្រុមគេមើលអីចឹងទៅណាស។

ដានី ៖ ១០គ្រួសារហ្នឹង?

ផន ៖ បាទ! ១០គ្រួសារហ្នឹង។

ដានី ៖ អីចឹងប្រពន្ធអឹក៏មកនៅជាមួយគេ១០គ្រួសារហ្នឹងដែរ?

ផន ៖ បាទ នៅហ្នឹងដែរ ហើយខ្ញុំក៏ចេញទៅទៀតទៅ។

ដានី ៖ ចុហប្រពន្ធកូនធ្វើអីទៀតទៅ?

ផន ៖ ប្រពន្ធកូនអត់ធ្វើផង ជូនទៅគេគ្រាន់តែឲ្យទៅស្ទូងៗទៅ បើឲ្យទៅច្រូតៗទៅណាស អាហ្នឹងខែច្រូត។

ដានី ៖ ពេលនៅក្នុងព្រៃហ្នឹងមានស្ទូងមានច្រូតដែរ?

ផន ៖ បាទ!មានដាំ គេហៅដាំស្រូវអាយើងស្រូវគ្រាប់ត្រសក់គ្រាប់ត្រប់គេហ្នឹងដាំ។ ពេលដែលដាំហ្នឹងការពារដែរហ្នឹងណាស គេហៅថា កាប់យើងម៉ាជ្រលងៗចឹងយើងដាំបាន។ កាលណាតួស្វរកប៉ាល់ហោះយើងធ្វើម៉េចប្រុងប្រយ័ត្នអីចឹងទៅ នាំគ្នាវាកទៅរកព្រៃល្បះចឹងទៅ។

ដានី : មានកប៉ាល់ហោះទំលាក់ដែរ?

ផន : ហ្អូស!មានដែរតើ ។

ដានី : មានទំលាក់ចំដែរអត់?

ផន : អត់អីទេ មិនដែលចំទេ ។

ដានី : តែមានទំលាក់ដែរ?

ផន : មានក្បែរៗហ្នឹងដែរហ្នឹងណាស ដូចអ្នកដែលចេញទៅនេសាទទៅអីចឹងវាឲ្យពង់ (ស្តាប់អត់ច្បាស់) មក វាបាញ់ម៉ាគ្រាប់ចឹងវាឲ្យពង់មក ដល់ស្អែកបានវាមកដាក់ ។

ដានី : ចុះនៅក្នុងព្រៃអីចឹងធ្វើផ្ទះធ្វើអីនៅ?

ផន : ហ្អូស!យ៉ាប់ណាស់អារឿងផ្ទះនៅហ្នឹង ទិញអាដែងសំពត់ភ្លៀងហ្នឹងណាសម៉ានៅៗហ្នឹងឯង ហើយមុងក៏ដេកដាចវេទនាមែនទែន ។

ដានី : ចុះហូបចុកអីគ្រប់គ្រាន់ដែរទេបើយើងដាំស្រូវតិចចឹង?

ផន : អារឿងហូបហ្នឹងខ្វះខាតដែរ យើងតាំងពីបេះបន្លែ ព្រលិត ជួនទៅកាត់អាក្តិលចេកយើងហ្នឹង ហើយមិនមែនអាចេកយើងនេះទេ គេហៅអាចេកគ្រាប់យកអាក្តិលវាហ្នឹងមកចិតៗចឹងទៅ ហើយយកអាខ្លាញ់ត្រីយើងហ្នឹង ព្រោះយើងនៅក្នុងព្រៃវាសំបូរខ្លាញ់ណាស់ត្រី ដាក់មងបានអីយកមកជំហ៊ារខ្លាញ់បានយកទៅចៀន ។

ដានី : ចៀនក្តិលចេកហ្នឹង?

ផន : បាទ!ចៀនក្តិលចេកហ្នឹង បើមានយកជ្រលក់ទឹកឃ្មុំទៅចៀនទៅគ្រាន់មានជាតិផ្អែមហូបក្រែងលខ្វះអីហូបខ្លាំងណាស ។

ដានី : តែអឹកាលនោះយើងមានធ្វើសកម្មភាពក្នុងភូមិដូចចូលមកយកអង្ករមានអីទេពីក្នុងភូមិ?

ផន : វាមិនងាយនឹងយកបានទាល់តែទ័ពគេមកតែម្តងបានៗ បើថាទ័ពគេដូចថាគេចូលមកបានប្តុគេមានបណ្តាញគេចឹងទៅ គេឲ្យពួកប្រជាជនខាងក្នុងយកអង្ករចេញមកឲ្យយើង ។

ដានី : អីចឹងអឹមកដល់៧៥គេចាត់ឲ្យមកឃ្វាលគោហ្នឹងបានរយៈពេលប៉ុន្មានដែរ?

ផន : ឃ្វាលគោបានប្រហែលពីរខែបីខែទេដឹង មកភ្ជួរផងឃ្វាលផងម្ងោះហើយទីបញ្ឈប់ហ្នឹងតែម្តង ។

ដានី : កាលនោះពេលយើងមកឃ្វាលគោហ្នឹងអឹបែកពីគ្រួសារ?

ផន : បាទ!បែកហើយ ជួនកន្លះខែអីបានទៅជួបម្តងក៏មានដែរ ។

ដានី : ចុះកាលនោះបាយរួមឬបាយតាមគ្រួសារ?

ផន : អាហ្នឹងគេបាយតាមក្រុមណាស ។

ដានី : ម៉ាក្រុម១០គ្រួសារអីហ្នឹង?

ជន ៖ បាទ! តែម៉ាក្រុមហ្នឹងទៅ ឬជួនទៅគេឲ្យ បើយើងខ្ជិលដាំជាក្រុមអីចឹងគេឲ្យជាអន្លូរចឹងទៅ ចែកអន្លូរឲ្យដាំចឹងទៅ ។

ដានី ៖ តាំងពីចុង៧០ដល់ដើម៧២ពេលអឹទៅនៅខាងឪម៉ាល់ចូលព្រៃហ្នឹងគេចាប់ផ្ដើមបាយអីចឹងហើយ?

ជន ៖ មុនដំបូងឯកជនទេ ដល់ក្រោយមកគេចាប់រៀបជាក្រុមបណ្ដោយ ។

ដានី ៖ ជួនណាយើងដាំជាក្រុម ជួនណាទៅយើងដាំជាគ្រួសារចឹងទៅ?

ជន ៖ បាទ គេហៅថាខ្ជិលដំពាក់ដំពិនច្រើនណាសគេធ្វើចឹងទៅ ។

ដានី ៖ ដូចយើងទៅរកត្រីបានយើងចែកគ្នាចឹងទៅ?

ជន ៖ បាទ យើងចែកគ្នា គេបានក៏ចែកយើងមក ។

ដានី ៖ ដល់អឹថាទៅឃ្វាលគោហ្នឹង បាត់គោហ្នឹងបាត់ពេលឆ្នាំណា?

ជន ៖ មិនដឹងជានេះទេ គ្រាន់តែថានៅឆ្នាំ៧៥ហ្នឹងគឺបាត់គោ អារៀបចំហ្នឹងអារៀបនឹងថ្ងៃស្អែកហ្នឹងវាចប់ហើយ បានដឹងថាវាចប់ព្រោះគេវៃចូលភ្នំពេញអីអស់ហើយ ខ្ញុំ.... ។

ដានី ៖ បាត់គោអស់ប៉ុន្មាន?

ជន ៖ គោ វាយកទៅទាំងអស់ ។ គោទាំងអស់គេយកទៅទាំងអស់ មកដល់កៀងយកទៅបណ្ដោយមានសាវ៉ាន់ទីណែ បេស្ទឹងណា មកពេញបិប ហើយយើងមានទៅហ៊ានអី យើងបាតដៃទទេហ្នឹង ។

ដានី ៖ ខាងណាគេមកកៀងហ្នឹង?

ជន ៖ ខាងយើងប្រជាជន ។

ដានី ៖ ប្រជាជនអ្នកមកកៀងទេ?

ជន ៖ អត់ទេ ពួកស្អីមកខាងស្វាយត្រាង... ។

ដានី ៖ ទាហានស្វាយត្រាង ខាងខ្មែរក្រហមដែរ?

ជន ៖ អត់ទេ ខាងនេះគេ ខាង លន់ នល់ ។

ដានី ៖ ខាង លន់ នល់?

ជន ៖ បាទ ។

ដានី ៖ ចុះកាលថ្ងៃ១៧ មេសាខ្មែរក្រហមវាយកឈ្នះហើយ ពួក លន់ នល់ មកវាយយកគោទៀត?

ជន ៖ បាទ! អត់ដឹងទេ ប្រហែលពួកនោះមិនដឹងដែរតាមមើលទៅ មិនដឹងដូចគ្នាបានមកយក កុំអីបើដឹងប្រហែលជាអត់យកទេ ។

ដានី ៖ ខាងទាហាន លន់ នល់ ហ្នឹងអត់ដឹងថា...?

ជន ៖ បាទ ហើយទាហានខាងយើងក៏អត់ដឹងដែរ ខ្ញុំនៅក្នុងព្រៃក៏អត់ដឹងដែរដល់កៀនហើយបានដឹងថា ចប់បាត់ហើយ ដល់ចប់ហើយគេដកមកចូលយើងណោះវិញហើយ ខាងខ្មែរក្រហមអីណោះវិញ ហើយ ។

ដានី ៖ ចុះបាត់គោហើយយ៉ាងម៉េចទៀតអ៊ំ យើងទៅរាយការណ៍ប្រាប់ប្រធានគេឬយ៉ាងម៉េច?

ជន ៖ បាទ! ទៅប្រាប់ប្រធានគេ គេអត់ថាអីទេ ថាកុំភ័យវា គេវ៉ៃយកភ្នំពេញបានអស់ហើយមិនបាច់ ភ័យអីទៀត ចាំយើងទៅប្រមូលយកមកវិញឲ្យអស់ទៅ អានេះភាសាគេអីចឹងណាស ។

ដានី ៖ ប្រធានឈ្មោះអីគេអ៊ំទៅរាយការណ៍ប្រាប់?

ជន ៖ ទេ មិនដឹងឈ្មោះអីទេ ខ្ញុំអត់បានទៅរាយការណ៍ទេមានគេអ្នកទៅផ្ទាល់ទៀត ព្រោះមិនងាយ ចូលទៅបានទេ គេមានមន្ទីរគេអត់ចូលបានទេ ។

ដានី ៖ មន្ទីរនៅឯណា?

ជន ៖ មន្ទីរនៅក្នុងព្រៃ ។

ដានី ៖ គេហៅមន្ទីរអីអាហ្នឹង.

ជន ៖ មិនដឹងមន្ទីរស្អីទេហ្នឹង តែគ្រាន់តែដឹងថានៅក្នុងមន្ទីរនោះបើថាចូលទៅ ដូចក្មួយឯងអីចូលទៅបាន ដូចខ្ញុំចូលមិនបានទេណាស ។ ក្នុងកំឡុងឃ្វាលគោទាំងអស់ហ្នឹង ចូលទៅបានតែមេគេម្នាក់ទេ ដែលអាចចូលទៅបានកន្លែងហ្នឹងរាយការណ៍អី ។

ដានី ៖ មេឃ្វាលគោហ្នឹងឈ្មោះអី?

ជន ៖ មេឃ្វាលគោនោះមិនដឹងឈ្មោះអីទេ ខ្ញុំមិនដឹងទេ មិនសូវចាំដែរ ។

ដានី ៖ ប៉ុន្មាននាក់ក្នុងក្រុមឃ្វាលគោហ្នឹង?

ជន ៖ យី! ច្រើនដែរហ្នឹង មានកំឡោះជំទង់អីចឹងទៅ វ័យចាស់ដូចខ្ញុំក៏មាន វាចំរុះណាស ។

ដានី ៖ ចំរុះប្រហែលគ្នាប៉ុន្មាននាក់?

ជន ៖ ប្រហែលគ្នា៨,១០នាក់ទេដឹង ។

ដានី ៖ ប្រហែល៨,១០នាក់ហ្អី?

ជន ៖ បាទ ។

ដានី ៖ អីចឹងដល់ពេលបាត់គោនៅថ្ងៃបែកភ្នំពេញតែម្តង?

ជន ៖ បាទ! ថ្ងៃបែកតែម្តង ។

ដានី ៖ ថ្ងៃ១៧ មេសា ឆ្នាំ៧៥?

ផន ៖ បាទ ដល់ព្រឹកព្រលឹមឡើងដឹងថាបែកបាត់ទៅហើយ ដល់បែកហើយមានអីទៀត ។ ចុះយើងថាទៅប្ដឹងគេ គេថាមិនបាច់ភ័យអីទេ គង់តែរបស់យើងទេយើងបែកហើយហ្នឹង ។

ដានី ៖ អីចឹងបែកឆ្នាំ៧៥ហើយគេបញ្ជូនអ៊ំមកឱម៉ាល់បត់ត្រង់វិញ?

ផន ៖ បាទ ។

ដានី ៖ បញ្ជូនមកខាងឱម៉ាល់បត់ត្រង់ហ្នឹង...

ផន ៖ ប្រជាជនធម្មតា ។

ដានី ៖ ចុះអ៊ំថាគេចាត់តាំងឲ្យធ្វើមេភូមិ?

ផន ៖ ដល់មកដល់រួចហើយបានគេរៀបចំប្រជុំ គេមើលសមត្ថភាពអីចឹងទៅបានគេរៀបចំចាត់តាំងឲ្យខ្ញុំធ្វើជាស្មៀនក្រុមអីគេចឹងទៅ ។

ដានី ៖ ប៉ុន្តែអាដំបូងពេលអ៊ំឡើងមកដល់ភូមិបានរយៈពេលប៉ុន្មានបានគេប្រជុំ?

ផន ៖ ពីរបីថ្ងៃដែរ ។

ដានី ៖ ពីណាគេប្រជុំ?

ផន ៖ អាហ្នឹងពួកគេនែក! តា ក្រក ។

ដានី ៖ តា ក្រក?

ផន ៖ បាទ! តា ក្រក ។ តា ក្រក ហ្នឹងកាលមុនដូចថាគាត់ធ្វើទាហានណាស ។ គាត់ធ្វើទាហានហ្នឹងដូចថាគាត់ស្គាល់ខ្ញុំអីចឹងទៅ ថាយកមិត្ត ផន មួយទៅអាចទៅធ្វើបំរើការបានហើយ ក៏គេទាញខ្ញុំមក ។

ដានី ៖ ចុះ តា ក្រក កាលនោះគាត់នៅធ្វើអីកាលអ៊ំនៅតស៊ូក្នុងព្រៃក្នុងអី?

ផន ៖ អត់ទេ គាត់ខាងសេដ្ឋកិច្ចខាងអីដូចខ្ញុំដែរ តែគាត់ជាទ័ពណាស ជាទាហានមិនដឹងថាទាហានធ្លាក់បុណ្យឬយ៉ាងម៉េចយ៉ាងម៉ាខ្ញុំអត់ដឹងទេ ប៉ុន្តែគាត់ហ្នឹងប្រហែលជាក្តាប់ខ្ញុំតាមមើលណាស ។

ដានី ៖ ទាហានធ្លាក់បុណ្យយ៉ាងម៉េច? បានន័យថាទ័ពរបស់ខ្មែរក្រហមឬយ៉ាងម៉េច?

ផន ៖ បាទ ដូចថាវាមានវិបត្តិអីផ្សេងចឹងទៅណាស អត់ឲ្យយើងដើរជាទ័ពទៀតណាស់ គេឲ្យមកនៅជាប្រជាជនចឹងទៅណាស ។

ដានី ៖ មកគ្រប់គ្រងប្រជាជន?

ផន ៖ បាទ!មកគ្រប់គ្រងអីចឹងទៅណាស ដល់គាត់ស្គាល់ខ្ញុំអីចឹងទៅបានគាត់ហៅខ្ញុំទៅធ្វើ ។

ដានី ៖ ចុះអ៊ំស្គាល់ តា ក្រក តាំងពីឆ្នាំណាមក?

ផន ៖ តាំងពីឆ្នាំ៧៥ហ្នឹងឯង ។

ដានី ៖ ចុះអ៊ឹមានប្រសាសន៍អំបាញ់មិញថា ពេល តា ក្រុក ហៅអ៊ឹមកធ្វើការដែរហ្នឹងពីមុនមកគាត់ធ្លាប់ស្គាល់អ៊ឹហើយ?

ផន ៖ ស្គាល់ ស្គាល់ពេលទៅឃ្វាលគោនោះ ។

ដានី ៖ ស្គាល់ពេលឃ្វាលគោ?

ផន ៖ បាទ! តែគាត់នៅម៉ាផ្នែកនោះណាស ខ្ញុំទៅលេងអីចឹងទៅស្គាល់គាត់ ដល់គាត់ដូចថាបានគេប្រមូលឡើងមកចឹងទៅមកស្រុកវិញ គាត់ហៅខ្ញុំមកដែរ គាត់ស្គាល់ខ្ញុំ បានជាប់ខ្សែនោះមក ។

ដានី ៖ កាលនោះកាល តា ក្រុក គាត់ធ្វើកងទ័ពខ្មែរក្រហមនោះកាលនោះកងទ័ពរបស់គាត់កងអីវិញ?

ផន ៖ មិនដឹងយ៉ាងម៉េច មិនដឹងកងហា អាចថាមិនដឹងកងអីគាត់ទេ ។

ដានី ៖ កងទ័ពរបស់ស្រុក ឬរបស់តំបន់...?

ផន ៖ ប្រហែលជារបស់ស្រុកតាមមើល ។

ដានី ៖ របស់ស្រុកណា?

ផន ៖ ប្រហែលស្រុកព្រះនេត្រព្រះទេដឹង ឬយ៉ាងម៉េចទេខ្ញុំអត់សូវដឹង ព្រោះខ្ញុំនៅក្នុងព្រៃដែរ ។

ដានី ៖ ដល់ពេលមកប្រជុំប្រជាជនហ្នឹង តា ក្រុក គាត់ធ្វើអីអាហ្នឹង?

ផន ៖ បាទ កាលហ្នឹងប្រហែលជាគេចាត់តាំងអីគាត់ហើយបានគាត់មកហៅខ្ញុំថា "មិត្តឯងមកធ្វើជាមួយខ្ញុំមក ឥឡូវនៅជាមួយខ្ញុំសិន ព្រោះមិត្តឯងចេះអីតិចតួចចឹងណាសគ្រាន់តែសរសេរ" ព្រោះគាត់អត់ចេះសរសេរអីទេ ។

ដានីៈ តាក្រុកអត់ចេះទេ តាក្រុកអត់ចេះអក្សរទេ?

ផនៈ ទេ គាត់ចេះខ្លះដែរ មិនថាមិនចេះទេ គ្រាន់ចេះមើលបាន ។

ដានីៈ តាក្រុកគាត់ជាអ្នកស្រុកភូមិនៅណា?

ផនៈ ជាអ្នកសៀមរាម ។

ដានីៈ តាក្រុកជាអ្នកនៅសៀមរាប?

ផនៈ បាទ! តែមិនដឹងថានៅភូមិអីខ្ញុំអត់សូវស្គាល់ដែរ ។

ដានីៈ តាក្រុកគាត់ទៅប្រជុំអ៊ឹអីចាត់តាំងហ្នឹង កាលហ្នឹងចាត់តាំងអ៊ឹឲ្យធ្វើជាប្រធានភូមិ?

ផនៈ បាទ ។

ដានីៈ កាលហ្នឹងប្រធានភូមិណាទៅ?

ផនៈ ប្រធានភូមិហ្នឹងមិនទាន់ដឹងទេ នៅស្អីគេដងស្ទឹងក្រឡាញ់ដែរ គេឲ្យធ្វើហ្នឹង ធ្វើហ្នឹងបានតែពីរថ្ងៃក៏គេទាញខ្ញុំឡើងមកព្រះនេត្រព្រះនិងទៀត ។

ដានី៖ ទើបធ្វើប្រធានភូមិហ្នឹងបានតែពីរថ្ងៃទេ?

ជន៖ បាទ! ទើបបានពីរថ្ងៃ ។

ដានី៖ នៅដងស្ទឹងក្រឡាញ់ហ្នឹង?

ជន៖ បាទ ។

ដានី៖ អត់ស្គាល់ភូមិអីទេ?

ជន៖ ភូមិប្រហែលជាភូមិប្រាសាទដីង ប្រហែលប្រាសាទដីង ។

ដានី៖ ភូមិប្រាសាទ?

ជន៖ បាទ! តែមិនទាន់បានជារៀបចំអីទេណា គ្រាន់តែថាដូចជាប្រជុំគ្នាយើងចឹង ក្មួយឯងចាត់តាំងខ្ញុំទៅហើយមិនទាន់ថាបានយ៉ាងម៉េចទេ ស្រាប់តែក្មួយខាងនេះទាញខ្ញុំមកមួយទៀត ទាញខ្ញុំមកខាងព្រះនេត្រព្រះទៀតមក ខ្ញុំក៏ឡើងមកព្រះនេត្រព្រះវិញមក ។

ដានី៖ តាក្រុកគាត់ជាអ្នកចាត់តាំងឲ្យធ្វើជាប្រធានភូមិកាលហ្នឹងតាក្រុក គាត់មានតួនាទីអីគេ?

ជន៖ មិនដឹងជាទាទីអី ខ្ញុំអត់ដឹងទេ គ្រាន់ដឹងថា គាត់និងប្រហែលជាមានតួនាទីអីបានជាគាត់ហៅដូចថាគាត់រៀបចំចឹងណាស់ មិនថាស្រុកគេប្រជុំយ៉ាងម៉េចខ្ញុំអត់ដឹងទេ ។

ដានី៖ កាលហ្នឹងពីណាខ្លះទៅជាមួយតាក្រុក?

ជន៖ មើលខ្ញុំឃើញគ្នាច្រើនដែរ មិនដឹងជាអ្នកណាអ្នកណាទេ អស់ពីនោះដូចថាប្រធានក្រុមអីគាត់ចាត់តាំង ។

ដានី៖ បាទ ។

ជន៖ អ្នកណាអាចធ្វើជាក្រុមៗទៅមិនដឹងជាអ្នកណាអ្នកណាខ្លះខ្ញុំអត់មានចាំឈ្មោះដែលហ្នឹង យូរពេក ។

ដានី៖ ចឹងធ្វើប្រធានភូមិចាត់តាំងបានតែពីរថ្ងៃទេ?

ជន៖ បាទ ។

ដានី៖ ពីណាគេទាញអ៊ីមកខាងព្រះនេត្រព្រះ?

ជន៖ តាក្រុកនិងដែរ ។

ដានី៖ តាក្រុកដែរ?

ជន៖ បាទ! គាត់ថាឥឡូវខ្ញុំទៅនៅព្រះនេត្រព្រះហើយ ឥឡូវមិត្តឯងទៅជាមួយខ្ញុំ ។

ដានី៖ តាក្រុក គាត់ថា គាត់មកព្រះនេត្រព្រះ?

ជន៖ បាទ ។

ដានី៖ ហើយហៅអ៊ីមកនៅជាមួយ?

ជន៖ បាទ ។

ដានី៖ មកជាមួយមកតែពីរនាក់ទេ?

ជន៖ យី!គ្នាច្រើនដែរ គ្រាន់ថាជាប្រជាជនដូចៗគ្នា ។

ដានី៖ បាទ ។

ជន៖ បាទ!មកចឹងឲ្យគាត់នៅតាមភូមិៗរបស់គេចឹងទៅចូលៗតាមភូមិសិនទៅ ហើយបានគេរៀបចំថ្មីទៀតខ្ញុំអត់ដឹងទេ ហៅមកច្រើន ។

ដានី៖ ហៅមកច្រើន?

ជន៖ បាទ! ចេញពីព្រៃមកមានមនុស្សរាប់សិបនាក់ ។

ដានី៖ បានន័យថាមកច្រើនហ្នឹង ឲ្យមកនៅតាមភូមិហ្នឹងឲ្យមកធ្វើប្រធាននៅតាមភូមិ?

ជន៖ បាទ!អាហ្នឹងស្រេចគេចាត់តាំងទេ មកដល់និងពួកដែលនៅក្នុងព្រៃហ្នឹងគឺជាប្រធានគេហើយ ប្រធានក្រុមក៏មានប្រធានពួកក៏មានប្រធានភូមិក៏មាន គេចាត់តាំងឲ្យទាំងអស់ ។

ដានី៖ ចឹងអ៊ឹមកនិងមកនៅជាមួយតាក្រុក?

ជន៖ បាទ ។

ដានី៖ កាលហ្នឹងតាក្រុកមកតែពីរនាក់អ៊ីទេ មកគ្រប់គ្រងឃុំឬមានអ្នកផ្សេងទៀត?

ជន៖ បាទ!មកច្រើនដែរ តែមកគាត់ពង្រាយបញ្ចូលតាមភូមិទៅ ។

ដានី៖ បាទ ។

ជន៖ ហើយខ្ញុំទាំងពីរនាក់គាត់និងបានឡើងមកដល់កន្លែងឃុំគេនិងបណ្តោយ ។

ដានី៖ ឡើងមកដល់ឃុំ?

ជន៖ បាទ!កន្លែងឃុំព្រះនេត្រព្រះហ្នឹង ។

ដានី៖ ឃុំព្រះនេត្រព្រះ?

ជន៖ បាទ!ឃុំព្រះនេត្រព្រះ ។

ដានី៖ តាក្រុក គាត់ធ្វើប្រធានឃុំ?

ជន៖ បាទ!ដល់ហើយបានគេថា គាត់ហ្នឹងជាប្រធាន ហើយបានមិត្ត សន នោះទៀតគេជាអនុប្រធានអីចឹងណាស់ ។

ដានី៖ បាទ ។

ជន៖ មុនដំបូងគាត់មិនទាន់លើកខ្ញុំជាស្អីទេ គាត់ថាឥឡូវមិត្តឯងនៅជាមួយខ្ញុំសិនទៅ ចាំមើលខ្ញុំរៀបកំលាំងទៀត ។

ដានី៖ បាទ ។

ជនៈ ដល់នេះខ្ញុំនៅជាមួយគាត់ទៅគាត់ហៅឲ្យសរសេរអីខ្ញុំចេះតែសរសេរតិចៗទៅឲ្យគាត់ ហើយដល់ក្រោយមកបានគាត់ចាត់តាំងហៅមកថា មិត្តឯងនៅជាសមាជិកទៅ ។

ជានីៈ ជាសមាជិកឃុំ?

ជនៈ បាទ!សមាជិកឃុំ ។

ជានីៈ ចឹងតាក្រុក គាត់ធ្វើប្រធាន សន ជាអនុ?

ជនៈ បាទ ។

ជានីៈ សន ហ្នឹងគាត់មកពីខាងណាដែរ?

ជនៈ សន ហ្នឹងគាត់នៅអូរកំបុតយើងនេះ ។

ជានីៈ ខាងអូរកំបុត្រ?

ជនៈ បាទ!ស្ទឹងកំបុត ។

ជានីៈ ស្ទឹងកំបុត្រខាង?

ជនៈ បាទ!ស្ទឹងកំបុតខាងអន្លុងរបូរីហ្នឹង ។

ជានីៈ ស្ទឹងកំបុតអន្លុងរបូរី?

ជនៈ បាទ ។

ជានីៈ ចឹងតាក្រុក សន និងអ៊ំជាសមាជិក?

ជនៈ បាទ!សមាជិក ខ្ញុំសមាជិក ។

ជានីៈ សមាជិកទទួលខាងអី?

ជនៈ សមាជិកហ្នឹងមិនដឹងជាទទួលខាងអីទេ ខ្ញុំមិនសូវដឹងដែរ កាលហ្នឹងគេថាឲ្យជាសមាជិកចឹង ប៉ុនគេប្រើអីតែខ្ញុំនិងឯង កត់ក៏ខ្ញុំប្រើឲ្យធ្វើអីដូចថា រៀបចំកំលាំងអីក៏ខ្ញុំ ខ្ញុំមិនដឹងជាម៉េចទេអាហ្នឹងខ្ញុំមិនសូវដឹងដែលទេ គេរៀបចំចឹង ហើយអនុគេដើរជាមួយគ្នាគាត់ហ្នឹងពីរនាក់ហ្នឹង ។

ជានីៈ ពីរនាក់តាក្រុក ហើយ តា សន?

ជនៈ បាទ!អាហ្នឹងគាត់ដើរទៅណាប្រជុំធំអីគេពីរនាក់និងហើយ ខ្ញុំនៅតែកន្លែងចឹងទៅ ។

ជានីៈ ចឹងម្នាក់ទៀតដែលអ៊ំមានប្រសាសន៍ថា ឈ្មោះ ចាមនោះ?

ជនៈ បាទ!តា ចាមនិងក្រោមខ្ញុំទៀតដូចថាវាមានបួននាក់ហើយហ្នឹង ។

ជានីៈ បាទ ។

ជនៈ តា ចាមនិងចាត់តាំងក្រោយទេ ។

ជានីៈ ចឹងតា ចាមនិងក្រោមអ៊ំទៀត?

ជនៈ បាទ!អាហ្នឹងដូចថាបន្ទាប់ខ្ញុំដែលហ្នឹង អាហ្នឹងមិនដឹងថាគេហៅយ៉ាងម៉េចទេ ។

ដានី: ហៅថា សមាជិក ។

ជន: មានប្អូននាក់ហ្នឹង ។

ដានី: បាទ!ប្អូននាក់?

ជន: បាទ!ប្អូននាក់ហ្នឹង ។

ដានី: តាក្រុក គាត់ទទួលរួម?

ជន: បាទ ។

ដានី: តា សន គាត់ទទួលខាងអី?

ជន: តា សន ដូចថារបៀបម៉េចទេហ្នឹង អនុគេហ្នឹងខ្ញុំឃើញទៅណាតែពីរនាក់ហ្នឹង ទៅណាក៏ពីរនាក់ហ្នឹង ។

ដានី: បាទ ។

ជន: ហើយបើថាខ្ញុំវិញអត់ទេ ខ្ញុំនៅមួយកន្លែងដូចថារបាយការណ៍គេឲ្យមកសរសេរក៏សរសេរទៅ គេមិនឲ្យសរសេរដេកនៅហ្នឹង«សើច...»អត់មានធ្វើអីទេ ។

ដានី: ចឹងបែកភ្នំពេញឆ្នាំ៧៥ហ្នឹងបានពីរបីថ្ងៃ អ៊ឹមកភូមិបែកហើយបានពីរបីថ្ងៃគេប្រជុំ តាក្រុកទៅប្រជុំចាត់តាំង?

ជន: បាទ!ចាត់តាំងរៀបចំ ។

ដានី: ចាត់តាំងពីរថ្ងៃក្រោយមកព្រះនេត្រព្រះតែម្តង?

ជន: បាទ!គាត់ហៅឡើងមកព្រះនេត្រព្រះទៀត ។

ដានី: ចឹងអ៊ឹពេលហ្នឹងយើងចាប់ផ្តើមមានផែនការការណ៍យ៉ាងម៉េចទៅ ពេលអ៊ឹឡើងមកឃុំជាអ្នកសរសេររបាយការណ៍ ជាអ្នកចាត់តាំងអីហ្នឹង ដូចថាពេលហ្នឹងយើងចាប់ផ្តើមមានផែនការមានគោលនយោបាយរៀបចំស្រុកភូមិប្រជាជនយើងបែងចែកអីយ៉ាងម៉េច?

ជន: បាទ!អត់ដឹងទេក្មួយ អានេះគ្រាន់គេចាត់តាំងយើងដូចទីងមោងដែលហ្នឹង រឿងហ្នឹងខ្ញុំអត់សូវដឹងទេ អត់ដឹងអីសោះ គ្រាន់គេចាត់តាំងចឹង គេប្រើខ្ញុំឲ្យធ្វើអីខ្ញុំធ្វើនិងហើយ ព្រោះខ្ញុំអត់សូវដឹងដែរ ។

ដានី: កាលហ្នឹងគេប្រើឲ្យអ៊ឹធ្វើអីទៅ?

ជន: ជួនទៅមើលពួកអ្នកភ្ជួរចឹងទៅហើយភ្ជួរគេឲ្យទៅមើលស្រែ ដូចថាស្រែណាគេធ្វើដូចជាស្ទូងដកចឹងគេឲ្យខ្ញុំទៅមើលចឹងទៅ ខ្ញុំក៏ទៅប្រឡូកធ្វើនិងគេចឹងទៅ ទៅមិនថាឲ្យទៅឈរមើលទេ ទៅធ្វើដែរ ដូចជាភ្ជួរដីចឹង គេថាមិត្តឯងទៅខាងភ្ជួរដីខ្វះកំលាំងហើយទៅភ្ជួរដី មើលគេភ្ជួរដី

ពាក្យថាទៅមើលហ្នឹង យើងទៅធ្វើ គិតថាមើលអីរឿងហើយ អត់មានឲ្យយើងទំនេរបានទេ ធ្វើដូចគេចឹង គេអត់គេហូបអីយើងហូបហ្នឹង អត់មានប្រកែកថាបេះចុះអីទេ ។

ដានី: ចឹងកាលហ្នឹងអ្នកជម្លៀសមកពីភ្នំពេញអីមានឃើញមកនៅ?

ជន: មកដែលតើ មកតែគេពីរនាក់និងជាអ្នករៀបចំយ៉ាងម៉េចៗនៅលើគេ តាក្រក ហើយនិងតាសន ហ្នឹងគាត់ជាអ្នករៀបចំ ។

ដានី: ចឹងអ៊ំអត់មានបានចូលរួមទេ?

ជន: អត់ទេ ខ្ញុំអត់មានចូលប្រឡូកជាមួយ ព្រោះខ្ញុំវាថាដូចថា គេចាត់តាំងរបៀបប្រភេទយ៉ាងម៉េចទេ ។

ដានី: ចឹងអ៊ំកាលហ្នឹង ដូចជានៅក្នុងឃុំមួយចឹង គេចាត់តាំងប្រភេទប្រជាជនអីយ៉ាងម៉េច ប្រជាជនចាស់ ប្រជាជនថ្មី ប្រជាជនត្រៀម ប្រជាជនពេញសិទ្ធិអីយ៉ាងម៉េចដែរ?

ជន: អាហ្នឹងគេពីរនាក់នោះឯង ខ្ញុំអត់សូវដឹងទេ ។

ដានី: ពីរនាក់ហ្នឹងគេចាត់តាំង?

ជន: បាទ ។

ដានី: ប៉ុន្តែអ៊ំដូចថាដឹងថាគេចាត់តាំងមនុស្សប្រភេទយ៉ាងម៉េចបានគេចាត់ទុកថាប្រជាជនចាស់ពេញសិទ្ធិ មនុស្សប្រភេទយ៉ាងម៉េចបានគេចាត់ទុកចាស់ដែរ ដូចថាចាស់ត្រៀម បំរុងអីប្រជាជនថ្មីអីយ៉ាងម៉េច មនុស្សយ៉ាងម៉េចៗអ៊ំមានដឹងដែរ?

ជន: ខ្ញុំមិនសូវដឹងទេ ។

ដានី: បាទ ។

ជន: អត់ដឹងទេ គ្រាន់តែចាត់តាំងគេឲ្យធ្វើដូចថាគេឲ្យសរសេររឿងអីដូចថាប្រជាជនមកប៉ុននេះមាន ១០០នាក់ចឹងសរសេរតាមហ្នឹងទៅឲ្យគេទៅហើយអត់មានអីទៀតទេ របៀបដូចថាជាស្មៀន គេឲ្យយើងសរសេរ ឲ្យថារៀបចំចេញមកឲ្យខ្ញុំដឹងអីអត់ទេ ។

ដានី: អ៊ំដូចថាគេហៅក្នុងគណៈគេដែលយ៉ាងម៉េចបានជាអ៊ំអត់ដឹង?

ជន: បាទ!មិនដឹងជាយ៉ាងម៉េច ខ្ញុំអត់មានដឹងទេខ្ញុំ គេមិនឲ្យដឹងតែម្តង បើម្នាក់នោះទៀតគេអាចឲ្យដឹង ដូចថាតា ចាមនោះគេឲ្យដឹង ចំពោះខ្ញុំគេមិនសូវឲ្យដឹង ។

ដានី: តា ចាមតូចជាងអ៊ំទៀត?

ជន: បាទ!តូចតែគេមានខ្សែគេធំ ព្រោះខ្សែគេមកខាងតំបន់មកចាត់តាំងពីគាត់មក ។

ដានី: បាទ ។

ផនៈ ហើយខ្ញុំនេះប្រជាជនធម្មតា ចឹងដូចផ្ទះដូចជានៅក្រោមគេដដែលហ្នឹង ចឹងគេដឹងគ្នាគេពីរបីនាក់គេដឹង ខ្ញុំអត់ដឹងទេ ហើយធ្វើអីគ្រាន់ខ្ញុំចេះសរសេរតែប៉ុណ្ណឹងទេ គេសរសេរគេឲ្យសរសេរយ៉ាងម៉េចសរសេរតែតាមគេចឹងទៅ ។

ដានីៈ ចឹងកាលហ្នឹងអ៊ីមាននៅចាំថាគេសរសេរយ៉ាងម៉េចខ្លះ? ដូចថាគេកត់ប្រជាជនថ្មីអី?

ផនៈ បាទ! ប្រជាជនឧទាហរណ៍ថា គេអត់មាននិយាយថា ប្រជាជនប៉ុន្មានល្អអាក្រក់អីអត់ទេ គ្រាន់ថាប្រជាជនចូលមកថ្មីនេះប៉ុននេះ ខ្ញុំសរសេរប៉ុណ្ណឹងទៅប្រជាជនមានប៉ុណ្ណឹង ឥឡូវថាប្រជាជនទៅមុខធ្វើខាងស្ទូងដកប៉ុន្មាន ខ្ញុំសរសេរឲ្យគេទៅ ។

ដានីៈ ចឹងមានសរសេរថា ប្រជាជននេះជាប់ពាក់ព័ន្ធជាប់អី?

ផនៈ អត់ទេ ។

ដានីៈ ជាមន្ត្រីរាជការពីសង្គមចាស់ឬក៏ជាអ្នកមានអីត្រូវសរសេរទុកមួយដុំឬមួយយ៉ាងម៉េច?

ផនៈ ហ្នឹងក្រោយមកទៀតគេរៀបចំគ្នាគេផ្សេងទេ ខ្ញុំចុះហើយខ្ញុំធ្លាក់ហើយខ្ញុំធ្លាក់បុណ្យធ្លាក់តួនាទីតំណែងហើយតើ ដល់ពេលនោះខ្ញុំអត់មាននាទីអីទៀតទេ តែក្នុងនាមខ្ញុំនៅជាមួយគេដែរ ប៉ុន្តែខ្ញុំធ្វើការដូចជាប្រជាជនធម្មតា ខ្ញុំអត់មានដឹងអីទៀតទេ គេចាត់តាំងតែគ្នាគេផ្សេងទេ អាហ្នឹងអាម៉េចអាម៉ាលើគេហើយខ្ញុំធម្មតា ។

ដានីៈ ចឹងអ៊ីកាលហ្នឹងតាក្រក គាត់ធ្វើប្រធានឃុំព្រះនេត្រព្រះចឹង?

ផនៈ បាទ ។

ដានីៈ ចឹងខាងប្រធានភូមិប្រធានឃុំផ្សេងៗទៀតក្នុងស្រុកព្រះនេត្រព្រះអ៊ីមានស្គាល់ទេ ដូចជាឃុំភ្នំលៀបអី?

ផនៈ បាទ! កាលហ្នឹងខ្ញុំមិនសូវបានប្រជុំអីនិងគេខ្ញុំមិនសូវស្គាល់គេទេ ។

ដានីៈ ចឹងអ៊ីមិនដែលបានចូលរួមប្រជុំជាមួយគេទេ?

ផនៈ ទេ ប្រជុំដែរ តែវាមិនបានចាប់អារម្មណ៍ម្តងពីរដងចឹងណាស់ វាមិនបានប្រជុំដូចគេញឹកញាប់អី ព្រោះអានេះដូចគេហៅថា ចាត់តាំងចឹងដូនគេហៅក៏ទៅដូនគេមិនហៅទុកជាធម្មតា ។

ដានីៈ បាទ ។

ផនៈ វាមិនបានដូចគេខ្វាំងខ្វាអីអត់ទេ ។

ដានីៈ ចឹងព្រះនេត្រព្រះមានប៉ុន្មានឃុំកាលហ្នឹង?

ផនៈ ព្រះនេត្រព្រះមើល យី! មើលភូមិភ្នំលៀប ឃុំភ្នំលៀប ឃុំប្រាសាទ ឃុំទានកាំ ឃុំព្រះនេត្រព្រះ ។

ដានីៈ ព្រះនេត្រព្រះ ភ្នំលៀប ប្រាសាទ ទានកាំបួន?

ជនៈ បាទ!ដឹងណាទៀតទេ ខ្ញុំមិនដឹងឃុំណាទៀតខ្ញុំមិនសូវស្គាល់ ។

ដានីៈ ទឹកជោរ?

ជនៈ បាទ!ហ្នឹងហើយទឹកជោរមួយទៀត មកឃុំអីក្រោមមួយទៀតហៅឃុំអីទេ ខាងក្រោមស្ទឹង មិនដឹងហៅឃុំអី ហ្នឹងហើយឃុំប្រាសាទ ។

ដានីៈ ហើយចុះឃុំរហាលមានទេ កាលហ្នឹង?

ជនៈ បាទ!ឃុំរហាលមួយទៀត ។

ដានីៈ ចឹងកាលហ្នឹងឃុំជប់វ៉ារីអត់មានទេ?

ជនៈ ជប់វ៉ារីមាននៅព្រះនេត្រព្រះនិងឯងឃុំព្រះនេត្រព្រះនិងតែម្តង ។

ដានីៈ ចឹងជប់វ៉ារីអត់មានទេ?

ជនៈ បាទ!ជប់វ៉ារីដូចជាមិនមានទេ ។

ដានីៈ ចឹងមាន៦ឃុំ?

ជនៈ បាទ ។

ដានីៈ មានឃុំព្រះនេត្រព្រះ ឃុំភ្នំលៀប ឃុំទានកាំ ឃុំរហាល ឃុំប្រាសាទហើយឃុំទឹកជោរ?

ជនៈ បាទ ។

ដានីៈ ចឹងមាន៦ឃុំ?

ជនៈ បាទ ។

ដានីៈ ចឹងអ៊ំស្គាល់គណៈឃុំណាខ្លះ? គណៈដំបូងកាលពីឆ្នាំ៧៥?

ជនៈ ខ្ញុំស្គាល់តែតាក្រុក មួយទេ ។

ដានីៈ ស្គាល់តែតាក្រុក?

ជនៈ បាទ ។

ដានីៈ ចឹងឃុំផ្សេងៗទៀតអ៊ំអត់ស្គាល់ទេ?

ជនៈ បាទ!ដល់ពេលគេទម្លាក់ខ្ញុំបានចេញ មានឃុំគេដូចខាងនិរតីគេមកទទួលខុសត្រូវ ។

ដានីៈ កាលហ្នឹងគណៈស្រុកមានពីណាខ្លះគណៈស្រុកព្រះនេត្រព្រះ?

ជនៈ ចាំមើល ចាំតា ខូលមួយ តា អាត តា ម៉ោងបីនាក់ហ្នឹង ។

ដានីៈ បីនាក់ហ្នឹង?

ជនៈ បាទ ។

ដានីៈ តា ម៉ោង ពីណាគេធ្វើប្រធាន?

ជនៈ តា ម៉ោង ។

ដានី:	តា ម៉ោងធ្វើប្រធាន?

ជន:	បាទ ។

ដានី:	អនុ?

ជន:	តា អាត ។

ដានី:	សមាជិក?

ជន:	ខូល ។

ដានី:	តែបីនាក់និងទេ?

ជន:	បាទ ។

ដានី:	ចឹងកាលហ្នឹងនៅក្នុងតំបន់ប៉ុន្មាន?

ជន:	តំបន់៥ ។

ដានី:	គណៈតំបន់ពីណាគេ?

ជន:	ខ្ញុំដឹងថា តា ហ៊ុងហ្នឹងឯងហើយចុះពីនោះទៀតខ្ញុំអត់ដឹងទេ ព្រោះខ្ញុំឈប់មានតួនាទីអីហើយខ្ញុំធម្មតាហើយ ។

ដាវ៉ា:	ចឹងអីឆ្នាំណាតា ហ៊ុងត្រូវបានគេចាប់?

ជន:	មិនដឹងជាឆ្នាំណា ព្រោះពេលហ្នឹងខ្ញុំអត់ដឹងដែរ ខ្ញុំទៅជាប្រជាជនហើយប៉ុនវាគ្រាន់វាមិនប្រាប់ថាខ្ញុំនិងធ្លាក់ពីតួនាទីអីអត់ទេ គេប្រើឲ្យខ្ញុំចុះទៅទំនប់ទៅតែស្ទូងទៅដកនិងឯង ។

ដាវ៉ា:	អ៊ំនៅជាមួយតាក្រូក បានប៉ុន្មានឆ្នាំ?

ជន:	ខ្ញុំនៅបានប៉ុន្មាន តាំងពី៧៥,៧៦,៧៧បែកគ្នាអស់ហើយ ។

ដានី:	ចឹង៧៧បែកគ្នា?

ជន:	បាទ ។

ដាវ៉ា:	ចឹង៧៧មានចាំខែទេ ខែណាដែលគេចាប់តាក្រូកហ្នឹង?

ជន:	អត់ចាំ ។

ដានី:	ចឹងអ៊ំមានចាំជារដូវវិញ ឆ្នាំ៧៧វាមានពីររដូវ មានរដូវប្រាំង រដូវវស្សាអីចឹង?

ជន:	ខ្ញុំចាំកាលហ្នឹងដូចជារដូវភ្លៀង ។

ដានី:	ដើមរដូវភ្លៀងឬមួយកណ្ដាលឬមួយចុង?

ជន:	ពីព្រោះកាលនោះចេះ ខ្ញុំគេបញ្ជូនខ្ញុំគេចាប់តាក្រូក ហ្នឹង គេបញ្ជូនខ្ញុំមកស្ទូងនៅទំនប់អីទេមកលើខាងនេះវិញគេហៅស្ពានស្រែង ។

ដានី:	ស្ពានស្រែង?

ផន: បាទ ។

ដារ៉ា: ឆ្នាំណាអ៊ី?

ផន: ឆ្នាំដែលគេចាប់និងមិនដឹងជាឆ្នាំណាដែលគេចាប់ពួកតាក្រុកអីវ៉ាន់ហ្នឹង ពេលហ្នឹងខ្ញុំមកស្ទួងដល់ ហើយគេប្រមូលពីណាដែលធ្លាប់សត្តិសម្ព័ន្ធជាមួយតាក្រុកហ្នឹងណាស់ គេហៅមកទាំងអស់ដូច ជាខ្ញុំចឹងមានឈ្មោះចឹងមក មានឈ្មោះខ្ញុំដែរ គេហៅមកទាំងអស់គ្នា គេហៅមកដូចជាឃើញ ខ្ញុំយ៉ាងម៉េចដឹង គេអត់យកខ្ញុំ ក៏គេទុកឲ្យខ្ញុំធ្វើការនៅហ្នឹង មិនដឹងជាគេតាមដានយ៉ាងម៉េច គេឲ្យខ្ញុំធ្វើការ ខ្ញុំអត់ដែលគិតគូពីរឿងអីទេ ខ្ញុំមិនដែលនិយាយពីរឿងអីខ្ញុំគិតតែពីខំធ្វើ មួយ ថ្ងៃៗធ្វើគ្មានគិតពេលវេលាស្អីៗ ។

ដារ៉ា: អ៊ំនៅពេលដែលប្រមូលមកចាប់តាក្រុកនិងប្រមូលមកពីណាទៅប្រមូលកាលហ្នឹង?

ផន: ហ្នឹងសុទ្ធពួកគេហៅស្អីគេដែលនៅជាមួយតា ហ៊ុងហ្នឹង កាលហ្នឹងឃើញកូនឡានចឹង ឲ្យតែ ឃើញឡាននិងមកដឹងថាមកចាប់ហើយ មិនដឹងពួកណាទេ ។

ដារ៉ា: ចឹងពេលប្រមូលទៅហ្នឹងជួបតាក្រុក នៅជាមួយគ្នាហ្នឹង?

ផន: អត់ដឹងទេ ។

ដារ៉ា: មានជួបតាក្រុក ជាលើកចុងក្រោយទេ?

ផន: បាទ!ខ្ញុំនៅស្ពានស្រែងនោះ ។

ដារ៉ា: អត់ទេ ពេលដែលគេប្រមូលហៅទៅនិងណាស់មានបានជួបតាក្រុកទៀតទេ?

ផន: អត់ទេ បែកគ្នាតាំងពីអើយតែម្ដង ចុះតាក្រុក គាត់ចាត់តាំងខ្ញុំឲ្យទៅខាងទំនប់និងឯងឲ្យទៅ រហូតហើយគាត់មិនដែលហៅថាមិត្តឯងមកប្រជុំចេះចុះអត់ ខ្ញុំចេះតែធ្វើទៅអ្នកណាហៅអីមិន ដឹងទេ ។

ដារ៉ា: ហើយខាងកន្លែងតាក្រុក ធ្វើការងារភាគច្រើននៅជាការិយាល័យការងារគាត់នៅកន្លែងណា ទៅ?

ផន: បាទ!នៅព្រះនេត្រព្រះនិងតែម្ដង ។

ដារ៉ា: នៅឃុំនិងតែម្ដង?

ផន: បាទ!នៅក្នុងឃុំហ្នឹង ។

ដារ៉ា: នៅវត្តព្រះនេត្រព្រះ?

ផន: អត់ដល់ទេ គាត់នៅអីនេះមកខាងជើងវត្តនេះទេ ។

ដារ៉ា: មកជើង?

ផន: បាទ!មកជើងវត្តនៅជិតជើងភ្នំនិងដែរ អាហ្នឹងផ្ទះគាត់នៅហ្នឹងឯង ។

ដារ៉ាៈ នៅក្នុងអំឡុងពេលអ៊ំនៅជាមួយតាក្រុកហ្នឹង អ៊ំមានចាំព្រឹត្តិការណ៍មួយដែលគេប្រជុំនៅមុខវត្តព្រះនេត្រព្រះ មានព្រឹត្តិការណ៍មួយគេហៅប្រជាជនមកប្រជុំនៅវត្តព្រះនេត្រព្រះណាអ៊ំ អ៊ំព្យាយាមរកនឹកបន្តិចមើលអ៊ំ?

ជនៈ បាទ ។

ដារ៉ាៈ អ៊ំព្យាយាមរកនឹកមើលមានព្រឹត្តិការណ៍មួយហៅប្រជាជនមកប្រជុំនៅព្រះនេត្រព្រះហ្នឹង នៅឃុំព្រះនេត្រព្រះនៅជិតវត្តហ្នឹង ដូចថាតាក្រុកចូលរួមប្រជុំដែលអ៊ំមានបានចូលរួមប្រជុំកន្លែងហ្នឹងទេ?

ជនៈ ខ្ញុំដូចថាខ្ញុំវាដាច់ស្រយ៉ាលពីគេហើយ ។

ដារ៉ាៈ ពេលហ្នឹងអ៊ំមានដឹងថា ការប្រជុំគេហៅប្រជាជនមកប្រជុំមាននៅមុខព្រះនេត្រព្រះហ្នឹងទេ?

ជនៈ ខ្ញុំដូចជាមិនដែលអាហ្នឹង ។

ដារ៉ាៈ ព្រោះក្នុងពេលប្រជុំហ្នឹង មានសម្រេចដោតវាសនាចំពោះជនក្បត់ពីរនាក់អ៊ំ មានចាំទេកាលហ្នឹងដូចថាមានខុសសីលធម៌ មានខុសសីលធម៌គេហៅប្រជាជនប្រជុំហើយមកធ្វើជាមេទិញមួយ នៅកន្លែងវត្តព្រះនេត្រព្រះហ្នឹង អ៊ំមានចាំទេអាហ្នឹង?

ជនៈ មិនដឹងយ៉ាងម៉េចទេ អាហ្នឹង ។

ដារ៉ាៈ ព្រោះមានខុសសីលធម៌ពីរនាក់ មានប្រុសស្រីហើយគេយកមកកសាងមកប្រជុំនៅក្នុងវត្តព្រះនេត្រព្រះហ្នឹង អ៊ំមានចងចាំទេ កន្លែងហ្នឹង?

ជនៈ ខ្ញុំមិនសូវដឹងដែរ ។

ដារ៉ាៈ នៅពេលហ្នឹងតា ក្រុក គាត់ជាអ្នកប្រជុំកន្លែងហ្នឹង?

ជនៈ មិនដឹងជាយ៉ាងម៉េច ។

ដារ៉ាៈ ចឹងអ៊ំមានខស្សរាហ៍ដើរមកធ្វើការជាមួយតា ក្រុកអីកាត់វត្តព្រះនេត្រព្រះហ្នឹងទេ?

ជនៈ អាហ្នឹងដូចថា មួងម៉ាយាមអីហ្នឹង ។

ដារ៉ាៈ មានដើរកាត់តាមហ្នឹង?

ជនៈ បាទ ។

ដារ៉ាៈ នៅពេលដើរកាត់តាមហ្នឹង អ៊ំអត់មានពីណាដែលជួបប្រទះពេលណាដែកមានការប្រជុំគ្នាអីទេ ចួបជុំគ្នានៅក្នុងវត្តព្រះនេត្រព្រះហ្នឹង?

ជនៈ ទេ អត់មានដឹងទៀត ខ្ញុំមិនសូវដឹងទេរឿងហ្នឹង ។

ដារ៉ា: ព្រោះពេលហ្នឹងមានការកសាងបុរសនារីដែលខុសសីលធម៌ ហើយពេលហ្នឹងដូចថាមានសម្ភាប់ទាំងពីរនាក់ដងនៅមុខពេលប្រជុំហ្នឹង នៅមុខវត្តហ្នឹងកុំអ្នកផ្សេងៗកុំឲ្យយកគំរូតាម ចឹងពេលហ្នឹងអឺមានវត្តមាននៅក្នុងហ្នឹងទេ?

ជន: ទេ ប្រជុំត្រង់ណាទេ ។

ដារ៉ា: នៅមុខវត្តហ្នឹងមានដើមអំពិលបារាំងមួយអាធំមែនទេអឺ ដើមអំពិលបារាំងអាធំហ្នឹងនៅមុខវត្តព្រះនេត្រព្រះហ្នឹង?

ជន: បាទ! ដើមអំពិលបារាំងមានច្រើនចង់ងាប់ហ្នឹង ។

ដារ៉ា: តែនៅមុខវត្តហ្នឹងមានដើមអំពិលបារាំងមួយអឺមានដែលឃើញទេ នេះតាមយើងសម្ភាសសួរនាំពីមុនៗមកហ្នឹង ដូចថាមានការថា តា ក្រក គាត់ប្រជុំកសាងអ្នកខុសសីលធម៌នៅមុខវត្តហ្នឹង?

ជន: បាទ ។

ដារ៉ា: ហើយពេលហ្នឹងមានសម្ភាប់អ្នកដែលខុសសីលធម៌ហ្នឹងណាអឺ?

ជន: បាទ ។

ដានី: ហើយគេហៅប្រជាជនជាច្រើនមកមើលកុំឲ្យយកគំរូតាម អឺមានចាំទេ ព្រឹត្តិការណ៍ហ្នឹង?

ជន: មិនដឹងជាយ៉ាងម៉េចទេហ្នឹង ។

ដារ៉ា: អត់ដឹងទេ?

ជន: បាទ ។

ដារ៉ា: ចឹងនៅពេលអឺ ពេលដែលគេចាប់តា ក្រក ហើយអឺនៅស្រុកនៅឃុំព្រះនេត្រព្រះនិងបន្តទៀតប្តូមួយយ៉ាងម៉េច?

ជន: កាលហ្នឹងខ្ញុំផ្លាស់មកនៅភ្នំលៀបនោះ ។

ដារ៉ា: ចេញមកពីភ្នំលៀបវិញហើយ?

ជន: បាទ!ខ្ញុំមកភ្នំលៀបចុះខ្ញុំដាច់ខ្សែខ្ញែងពីនោះឯងហើយ ។

ដារ៉ា: នៅភ្នំលៀបហ្នឹងមកនៅពីណាជាមេភូមិភ្នំលៀបហ្នឹង?

ជន: អត់ទេ ខ្ញុំនៅនេះ ព្រោះខ្ញុំនៅធ្វើការនៅហ្នឹងតែម្តង នៅធ្វើការខាងទំនប់ ។

ដារ៉ា: អ្នកណាគ្រប់គ្រងភ្នំលៀប?

ជន: យាយ ចែម ។

ដារ៉ា: យាយ ចែម?

ជន: បាទ ។

ដារ៉ា៖ យាយ ចែម គាត់មានទីតាំងនៅកន្លែងភ្នំលៀបឬគាត់ជាមេឃុំភ្នំលៀប?

ជន៖ គាត់មិនមែនជាមេឃុំទេ គាត់ជាគណៈតំបន់ដឹង បើមិនតំបន់ស្រុកហ្នឹងឯង បើមិនស្រុកតំបន់ហើយ ព្រោះគាត់ទទួលខុសត្រូវទាំងអស់ ខ្ញុំដូចជាមិនសូវដឹងដែរ ។

ដារ៉ា៖ ស្រែងចែងចឹង កន្លែងអ៊ីទៅធ្វើការ?

ជន៖ ស្ពានស្រែង ។

ដារ៉ា៖ ពីស្ពានស្រែងមកភ្នំលៀបហ្នឹងឆ្ងាយទេ អ៊ី?

ជន៖ ស្ពានស្រែងឆ្ងាយដែរ ដើមម៉ាព្រឹកដឹង ។

ដារ៉ា៖ ឆ្នាំណាដែលអ៊ីទៅនៅស្ពានស្រែងហ្នឹង?

ជន៖ វាពិបាកទៀតខ្ញុំ ព្រោះអាហ្នឹងវាចលាចលហើយ វាចលាចលហើយបានខ្ញុំបានទៅនៅនោះឯង អាហ្នឹងគេចាប់អស់ហើយហ្នឹង ចាប់ពួកហ្នឹងអស់ហើយបានខ្ញុំទៅនៅនោះ ។

ដារ៉ា៖ ចឹងនៅពេលដែលចាប់តា ក្រុក ហ្នឹងពេលហ្នឹងគេហៅទៅជួបហ្នឹងមានពីណាឡើងជាឃុំជំនួសតា ក្រុកហ្នឹង?

ជន៖ អាហ្នឹងតា ណុញ ។

ដារ៉ា៖ ចឹងឈ្មោះ ណុញឡើងជំនួយតា ក្រុក?

ជន៖ បាទ ។

ដារ៉ា៖ ចឹងណុញហ្នឹងមកពីខាងណាអ៊ី?

ជន៖ មកពីខាងនិរតី ។

ដានី៖ ចឹងបន្ទាប់ពីណុញមកមានពីណា?

ជន៖ ឈ្មោះ ថា ។

ដារ៉ា៖ ឈ្មោះ ថា ហ្នឹងជាអនុ?

ជន៖ បាទ!ជាអនុ ។

ដារ៉ា៖ ហើយចុះសមាជិក?

ជន៖ សមាជិកមិនដឹងជានរណាទេ ខ្ញុំអត់សូវដឹងដែរ ។

ដារ៉ា៖ ហើយយ៉ាងម៉េចបានជាអ៊ីដឹងថា ណុញ ជាប្រធានឃុំ ឈ្មោះ ថា ជាអនុប្រធានឃុំ?

ជន៖ បាទ!ពេលដែលគេចាត់តាំងខ្ញុំទៅហ្នឹងហើយ ដល់ពេលឡើងប្រជុំដូចថា គេឡើងមកប្រជុំនៅភ្នំលៀបហ្នឹងមានពីរនាក់ហ្នឹងឯងដែលជាប្រធានឃុំគេ ។

ដារ៉ា៖ អ៊ីចូលរួមប្រជុំនិងគេដែរ?

ជន៖ បាទ!ចុះពួកក្រុមៗគេហៅមកទាំងអស់ អាក្រុមអ្នកធ្វើការហ្នឹងគេហៅមកប្រជុំទាំងអស់ ។

ដារ៉ាៈ ពេលចូលរួមប្រជុំហើយអ៊ំទៅណាទៀត គេចាត់តាំងឲ្យទៅធ្វើការនៅស្ថានស្រែង?

ជនៈ បាទ ។

ដារ៉ាៈ ហើយស្ថានភាពការងារនៅស្ថានស្រែងហ្នឹងវាយ៉ាងម៉េចដែលអ៊ំ?

ជនៈ ពេលនោះទឹកវាហូរមកដាច់សំណាបដាច់អីអស់ ហើយគេបញ្ជូនខ្ញុំមកភ្នំលៀបវិញ មកភ្នំលៀបដើម្បីមកជួយច្រូតស្រូវដែលវាលិចទឹកហ្នឹង ទឹកវាបុកមកខ្លាំង អាហ្នឹងឆ្នាំដែលគេចាប់អស់ហើយហ្នឹង ខ្ញុំគេបញ្ជូនមកភ្នំលៀបមក ។

ដានីៈ ចឹងកាលពីអ៊ំនៅជាមួយតា ក្រុកហ្នឹង តា ក្រុកឲ្យអ៊ំសរសេរអីអ៊ីខ្លះទៅក្រៅពីអ៊ំរៀបរាប់មិញសរសេររបាយការណ៍?

ជនៈ គ្រាន់តែសរសេរថា ធ្វើស្រែហ្នឹងបានប៉ុន្មានហិចតាឲ្យខ្ញុំសរសេរចឹងទៅ ហើយគាត់យករបាយការណ៍ហ្នឹងឡើងឲ្យស្រុកចឹង ដូចថាភ្ជួរហ្នឹងបានប៉ុន្មាន? ហើយអ្នកស្ទូងហ្នឹងបានប៉ុន្មាន? ហើយស្ថិតិទៅយើងឲ្យគេ ។

ដានីៈ ចឹងកាលនៅជាមួយតា ក្រុក កាលហ្នឹងមន្ទីរសន្តិសុខរបស់គេនៅកន្លែងណាទៅ?

ជនៈ នៅផ្ទះហ្នឹងដឹង ។

ដានីៈ នៅផ្ទះតា ក្រុក តែម្តង?

ជនៈ បាទ! នៅផ្ទះហ្នឹង អត់មានដាក់ណាដាក់ផ្ទះហ្នឹង តែមិនដឹងថាយ៉ាងម៉េចម៉ាទេ ។

ដានីៈ អ្នកដែលគេចាប់មកច្រើនតែប្រភេទអីដែរ?

ជនៈ ខ្ញុំមិនដឹងថា ជាប្រភេទអីទេ ពេលនោះវាច្របូកច្របល់ពេកទៅណាស់ ។

ដានីៈ ចឹងអ៊ំកន្លែងមន្ទីរសន្តិសុខរបស់ស្រុកព្រះនេត្រព្រះនៅណា?

ជនៈ បាទ! អាហ្នឹងមកពីផ្លូវថ្នល់?

ដានីៈ នៅណា?

ជនៈ នៅថ្នល់យើងកន្លែងត្រង់ផ្សារហ្នឹង ផ្ទះថ្មមួយ ។

ដានីៈ ផ្ទះថ្មមួយ?

ជនៈ បាទ! អាផ្ទះថ្មមួយនៅខាងនោះ យើងទៅពីនេះនៅខាងឆ្វេងដៃ?

ដានីៈ នៅខាងឆ្វេង?

ជនៈ បាទ ។

ដានីៈ នៅជាប់ផ្សារព្រះនេត្រព្រះហ្នឹង?

ជនៈ បាទ! មកពីលិចផ្សារបន្តិច ។

ដានីៈ មកលិចផ្សារព្រះនេត្រព្រះ?

ជន:	បាទ ។

ដានី:	ហ្នឹងមន្ទីរសន្តិសុខរបស់ស្រុកព្រះនេត្រព្រះ?

ជន:	មិនដឹងយ៉ាងម៉េចទេ ខ្ញុំដឹងថាអាហ្នឹងកន្លែងស្រុកគេហើយហ្នឹង ។

ដានី:	កន្លែងស្រុកគេ?

ជន:	បាទ ។

ដានី:	កន្លែងគេចាប់មនុស្សអីដាក់ហ្នឹង?

ជន:	បាទ!មិនដឹងជាម៉េច ។

ដានី:	តែមានដែលឃើញគេចាប់ដាក់ហ្នឹងដែលអត់ទេ?

ជន:	អត់ដឹងទេ ខ្ញុំដឹងកន្លែងតា ក្រក ហ្នឹងឃើញផ្ទះគាត់ហ្នឹង ។

ដានី:	ចឹងអ៊ំមានប្រសាសន៍មិញថា មានពួកបស្ចឹមគេចូលមក?

ជន:	បាទ ។

ដានី:	បស្ចឹមចូលមកឆ្នាំណា?

ជន:	មិនដឹងជាឆ្នាំប៉ុន្មាន បស្ចឹមចូលមកហើយមានពួកនិរតីបានគេមកនេះ ។

ដានី:	ចឹងពួកបស្ចឹមគេចូលមកមុននិរតី?

ជន:	បាទ!មកមុន ។

ដានី:	ពួកបស្ចឹមហ្នឹងគេចូលមកធ្វើអី?

ជន:	បាទ!គេចូលមកគ្រប់គ្រងមិនដឹងជាយ៉ាងម៉េចទេ គេចូលមកគេរៀបចំជាក្រុមជាកងគេណាស់ ហើយដូចជាពួកខ្ញុំអីហ្នឹង គេឈប់អើពើទាំងអស់ហើយឥឡូវហ្នឹង ដល់និរតីមកទៀតចាប់ពួកបស្ចឹមម្តងទៀត ។

ដានី:	ចាប់ពួកបស្ចឹមម្តងទៀត?

ជន:	បាទ!មិនដឹងជាចាប់យ៉ាងម៉េចអីយ៉ាងម៉េចខ្ញុំមិនសូវដឹងដែរ ។

ដានី:	ចឹងពួកបស្ចឹមចូលមកពួកតា ក្រកតា អីហ្នឹងគេចាប់នៅ?

ជន:	តា ក្រកហ្នឹងគេរំលាយហើយ គេលែងចង់អើពើហើយ ។

ដានី:	តែគេមិនទាន់ចាប់ទេ?

ជន:	បាទ!គេមិនទាន់ចាប់ទេ ។

ដានី:	ចឹងពួកនិរតីមកអ៊ំមានចាំខែ ចាំឆ្នាំទេ? ដែលពួកបស្ចឹមចូលមក?

ជន:	បស្ចឹមក៏អត់ចាំហើយនិរតីក៏អត់ចាំ មិនចាំទេ ។

ដានី:	មកយូរទេ ពួកបស្ចឹមមកបានរយៈពេលប៉ុន្មានបានពួកនិរតីមកតាមក្រោយ?

ជនៈ មិនដឹងជាមកប៉ុន្មានខែ ប៉ុន្មានថ្ងៃទេនេះ តែគ្រាន់តែមករៀបចំបានហើយ ឃើញនិរតីមកដល់ទៀតចេះ មិនបានជាចាំថាថ្ងៃខែយ៉ាងម៉េចអត់ទេ ។

ដានី: ចឹងនៅពេលពួកនិរតីមក ពួកបស្ចឹមត្រូវគេចាប់យកទៅដែរ?

ជនៈ បាទ!អត់ទេ គ្រាន់តែរំលាយដូចថាគេបំបែកអាក្រុមធំ ដូចថាគេកងធំចឹងឲ្យនៅក្នុងកងតូចហើយកងតូចហ្នឹងមកនៅក្រុមអីចឹង គេបំបែងចឹងហើយ គេឡើងទៅទៀតទៅ ។

ដានី: ចឹងនៅពេលពួកនិរតីមកតា ក្រុក អីហ្នឹងគេចាប់? ហើយពួកនិរតីគេបំបែកចឹង? អះ!ពួកបស្ចឹមគេបំបែក?

ជនៈ បាទ!បំបែក ។

ដានី: ហើយតា ក្រុកហ្នឹងគេចាប់ផ្តើមចាប់ ពួកនិរតីអ្នកចាប់ឬពួកណាអ្នកចាប់?

ជនៈ ដឹងអ្នកណាអ្នចាប់ទេ ខ្ញុំអត់សូវដឹងទេ តាមមើលមានពីណាមានតែនិរតីហ្នឹងឯងជាអ្នកចាប់នោះ ចុះមិនដឹងថាអ្នកណាចាប់ បស្ចឹមអត់មានចាប់ទេ បើចាប់មានចាប់និរតីហ្នឹងឯង ។

ដានី: តា ក្រុក តា សន គេចាប់?

ជនៈ បាទ!តា សន គាត់អនុគេ ដូចថាខុសសីលធម៌ ស្លាប់មុនគេចាប់ ។

ដានី: គេសម្លាប់មុនទៀត?

ជនៈ បាទ! ។

ដានី: ពីណាជាអ្នកសម្លាប់?

ជនៈ ទេ មិនដឹងដូចថាមានអ្នកសម្លាប់ម៉េចមិនដឹងទេ ខ្ញុំអត់ដឹងទេ តែដឹងថាខុសសីលធម៌ ។

ដានី: ខុសសីលធម៌ហ្នឹងក្រុមតា ក្រុក ជាអ្នកចាប់ឬមួយយ៉ាងម៉េច?

ជនៈ អត់ទេ អាហ្នឹងខាងស្រុកគេជាអ្នកចាប់ទេ ។

ដានី: ខាងស្រុក?

ជនៈ បាទ ។

ដានី: ខាងស្រុកខាងណា?

ជនៈ មិនដឹងជាខាងណាខ្ញុំមិនសូវដឹងដែរ តែដឹងថាគេចាប់ហើយតា សន ហ្នឹង ។

ដានី: តា សន គេចាប់មុនគេសម្លាប់ចោលនៅហ្នឹងទេ?

ជនៈ បាទ!មិនដឹងជាស្លាប់អីណាអត់ដឹង ។

ដានី: ចឹងចុះតា ចាម?

ជនៈ តា ចាម ក៏អត់ដឹងដែរ ។

ដានី: តា ចាម គេចាប់ដែលឬអត់ទេ?

ជន: បាទ!ចាប់ទាំងអស់ ។

ដានី: ចុះខាងស្រុក ដូចជា តា ម៉ោង តា អាត ថា ខូលអី?

ជន: អាហ្នឹងស្រាប់តែបាត់ៗ ទៅថាឡើងទៅរៀនខ្ញុំអត់សូវដឹងដែរ ។

ដានី: ដល់ហើយពួកនិរតីមកជំនួសវិញ?

ជន: បាទ ។

ដានី: នៅខាងឃុំព្រះនេត្រព្រះឈ្មោះ ណុញ មកពីនិរតី?

ជន: ណុញ មកពីនិរតី ។

ដានី: ចុះឈ្មោះ ថា?

ជន: ថា ក៏មកពីនិរតី ។

ដានី: ថា ហ្នឹងស្រី?

ជន: ស្រី ។

ដានី: ក្មេងទេ កាលហ្នឹង?

ជន: ក្មេងដែលហ្នឹង ។

ដានី: ចុះ ណុញ?

ជន: ណុញ គេហៅថាមនុស្សកណ្ដាលដែរ ប្រហែលជា៥០ ។

ដានី: ក្នុងមនុស្សពីរនាក់ហ្នឹង អ៊ំនៅក្នុងជាសមាជិករបស់ឃុំគេដែលឬមួយអត់ទេ?

ជន: អានេះដូចនិយាយថា នៅក្នុងសមាជិកគេក៏មិនដឹងបើថា សមាជិកគេដូចមិនមែនជាសមាជិក
ទេ ពីព្រោះគេអត់មានសូវអើពើនិងខ្ញុំផងហ្នឹង គេគ្រាន់ចាត់តាំងឲ្យខ្ញុំទៅ ។

ដានី: គ្រប់គ្រង?

ជន: បាទ! ទៅគ្រប់គ្រងនោះ ។

ដានី: ចឹងចាត់តាំងអ៊ំឲ្យទៅមើលកងចល័តនោះ?

ជន: បាទ! ទៅមើលកងចល័តនោះ ។

ដានី: មើលចល័តនៅស្ពានស្រែង?

ជន: បាទ! តែមិនដឹងថា យ៉ាងម៉េច ។

ដានី: ចឹងកាលហ្នឹង តា ម៉ោង តា អាត តា ខូលហ្នឹងមិនជាគណៈស្រុកព្រះនេត្រព្រះ?

ជន: បាទ ។

ដានី: គេចាប់អស់ទៅខាងនិរតីមកឡើងមានពីណាខ្លះ?

ជន: ខ្ញុំដឹងថា ឃុំដឹងតែពីរនាក់ហ្នឹងឯង ។

ដានី៖ ចឹងដល់ពេលស្រុក?

ជន៖ ស្រុកដឹងថា យាយ ចែម មួយ ។

ដានី៖ យាយ ចែម?

ជន៖ បាទ! យាយ ចែម ខ្ញុំដឹងតែប៉ុណ្ណឹងឯង ក្រៅពីហ្នឹងអត់ដឹងដែរ ។

ដានី៖ ចឹងអ៊ំនៅក្នុងសមាជិកគណៈឃុំព្រះនេត្រព្រះដដែល តែគេចាត់អ៊ំឲ្យទៅខាងស្ពានស្រែង?

ជន៖ បាទ!តែមិនដឹងគេចាត់តាំងរបៀបប្រភេទយ៉ាងម៉េច ព្រោះខ្ញុំទៅធ្វើការដូចគេដែលហ្នឹង ។

ដានី៖ ចឹងអ៊ំទទួលចល័ត អ៊ំនៅក្រោមចល័តរបស់ស្រុកដែលទៀតអត់?

ជន៖ បាទ!ខ្ញុំនៅក្រោមទាំងអស់ ខ្ញុំដូចថាគេឲ្យទៅថា អ្នកឯងទៅក្រុមនេះ ធ្វើការជាមួយគេអានេះ ចឹងទៅ ខ្ញុំទៅ ។

ដានី៖ ចុះចល័តស្រុកពីណាគេ កាលហ្នឹង?

ជន៖ ចល័តស្រុកមិនដឹងជាអ្នកណាអ្នកណីទេខ្ញុំ ពួកហ្នឹងមកគេចាត់តាំងថ្មីៗទៀត ខ្ញុំមិនដឹងដែល កាលចាស់ក៏អត់ដឹង ដឹងថាគេចាត់តាំងអ្នកណាអ្នកណី ។

ដានី៖ អ៊ំមានស្គាល់ឈ្មោះ សឿនទេ?

ជន៖ ទេ ខ្ញុំអត់ស្គាល់ទេ សឿនណាទេ កំពុងតែរកនឹកសឿន មិនដឹងជាសឿនណា ។

ដានី៖ ចឹងអ៊ំនៅពេលយាយ ចែម មកគ្រប់គ្រប់ស្រុកព្រះនេត្រព្រះ ផ្ទះគាត់នៅភ្នំលៀបចឹង?

ជន៖ បាទ ។

ដានី៖ ចុះមន្ទីរសន្តិសុខគេនៅណា?

ជន៖ យី!មន្ទីរសន្តិសុខមិនដឹងជាគាត់ដាក់ណាអត់ដឹងដែរ អត់ដឹងទេខ្ញុំ ។

ដានី៖ អត់ដឹងទេ?

ជន៖ បាទ ។

ដានី៖ ចឹងអ៊ំមានដែលឮមន្ទីរសន្តិសុខភ្នំទ្រយោង?

ជន៖ ឮមិនដឹងថា អាហ្នឹងក៏មិនដឹងម៉េចម៉ាខ្ញុំអត់សូវដឹងទេអាហ្នឹង ។

ដានី៖ ឮដែរ?

ជន៖ បាទ ។

ដានី៖ ធ្លាប់ឮថាអាហ្នឹងជាមន្ទីរយ៉ាងម៉េច មានដែលឮគេនិយាយថា យ៉ាងម៉េច?

ជន៖ មិនដឹងទេ គ្រាន់តែឮសូរគេថាមន្ទីរៗហ្នឹង មិនដឹងថានៅកន្លែងត្រង់ណាទេ ឮគេនិយាយចឹង ឯង ខ្ញុំអត់ដឹងដែរ តាមការពិតទៅដូចថា មនុស្សវាល្ងង់ដងវាមិនសូវដឹងអីឲ្យតែគេប្រើធ្វើ ម៉េចឲ្យតែបានបរមសុខ ។

ដានី៖ បាទ ។

ផន៖ បេះតែធ្វើទៅឲ្យបានសុខ បានសេក្តីសុខ ។

ដានី៖ ចឹងអ៊ំនៅកន្លែងស្ពានស្រែងហ្នឹងបានរយៈពេលប៉ុន្មានទៅ?

ផន៖ នៅបានបីបួនខែដែរ ។

ដានី៖ បាទ! បានបីបួនខែដែរ?

ផន៖ បាទ! ទាល់ទឹកស្រកវិញបានខ្ញុំមក ។

ដានី៖ មកខាងព្រះនេត្រព្រះវិញ?

ផន៖ មកនៅព្រះនេត្រព្រះវិញ ។

ដានី៖ មកនៅព្រះនេត្រព្រះមកនៅជាមួយ ណុញ ជាមួយ ថា ហ្នឹង?

ផន៖ អត់ទេ ខ្ញុំនៅដោយឡែកនៅជាមួយពួកបងប្អូនគេធ្វើនេះហ្នឹងឯង ពួកស្ទូងដកហ្នឹងនៅហ្នឹងជាមួយគេហ្នឹង ។

ដានី៖ តែប្រជុំអីជាមួយ ណុញ ជាមួយ ថា ដែរ?

ផន៖ អត់បានប្រជុំទេ តាំងពីពេលហ្នឹងមកអត់មានអីប្រជុំទៀតទេ បើប្រជុំទៅប្រជុំពួកខ្ញុំប៉ុន្មានក្រុមហ្នឹងឯង ។

ដានី៖ ក្រុមពីណាគេ?

ផន៖ ពួកយើងធ្វើយើងរបជុំអំពីស្រែយើងត្រូវធ្វើបានប៉ុន្មាន ធ្វើទៅបានផលយ៉ាងម៉េចៗប៉ុណ្ណឹងឯង ។

ដានី៖ ចឹងប្រពន្ធកូនអ៊ំនៅណាពេលហ្នឹង?

ផន៖ បាទ! គាត់នៅផ្ទះគាត់នៅព្រះនេត្រព្រះ ។

ដានី៖ ផ្ទះនៅម្តុំណា?

ផន៖ ផ្ទះពិបាកដែរ ផ្ទះនៅជិតវត្ត ។

ដានី៖ នៅភូមិជើងវត្តហ្នឹង?

ផន៖ បាទ ។

ដានី៖ ចឹងប្រពន្ធកូនអ៊ំធ្វើអីទៅ?

ផន៖ ដូចគេធម្មតាដក ស្ទូងអីដូចគ្នា គាត់អត់មានស្អីគេទេ ។

ដានី៖ គេមានឲ្យធ្វើប្រធាននារីអីនិងគេទេ?

ផន៖ អត់ទេ ធម្មតា ។

ដានី៖ កាលហ្នឹងអ៊ំមានកូនប៉ុន្មាន?

ជនៈ បាទ!មានកូនពីរ ។

ដានីៈ បានកូនពីរ?

ជនៈ បាទ!ប្រុសមួយស្រីមួយ ។

ដានីៈ កូនមមួយមានតាំងពីឆ្នាំ៧១?

ជនៈ បាទ ។

ដានីៈ តែដល់សម័យបីឆ្នាំហ្នឹងមានពីរទៀត?

ជនៈ បាទ!ហ្នឹងបានពីរទៀត បានពីរទៀតបានរត់ហើយហ្នឹង ។

ដានីៈ ចឹងយាយ ថែម នៅភ្នំលៀបចឹងកន្លែងធ្វើការគាត់នៅណាទៅ?

ជនៈ កន្លែងគាត់ធ្វើការនៅហ្នឹងឯង ។

ដានីៈ នៅណា?

ជនៈ នៅភ្នំលៀបហ្នឹង ។

ដានីៈ នៅភ្នំលៀបតែម្តង?

ជនៈ បាទ ។

ដានីៈ គាត់អត់មានមកធ្វើការនៅព្រះនេត្រព្រះទេ?

ជនៈ ព្រះនេត្រព្រះឃើញគាត់មកម្តងៗ តែកន្លែងដែលគាត់ធ្វើការពិតប្រាកដនៅភ្នំលៀបហ្នឹងហើយ ។

ដានីៈ នៅភ្នំលៀបហ្នឹងតែម្តង?

ជនៈ បាទ ។

ដានីៈ អ៊ំស្គាល់គាត់ច្បាស់ទេ?

ជនៈ ឥឡូវវាចង់ភ្លេចគាត់ដែលហ្នឹង វាយូរពេក ។

ដានីៈ តែកាលហ្នឹងស្គាល់គាត់ច្បាស់?

ជនៈ បាទ!ចុះរាក់ទាក់គ្នាដូចក្មួយនិងខ្ញុំចឹង ដូចថាមានការងារអីហ្នឹង គាត់ល្បែងទៅមើល ។

ដានីៈ គាត់ទៅមើលនៅណា?

ជនៈ គាត់ទៅមើលដូចជាខ្ញុំធ្វើការចឹង គាត់ទៅមើល ។

ដានីៈ អ៊ំទៅធ្វើការនៅណាខ្លះ គាត់ទៅមើល?

ជនៈ ដូចខ្ញុំធ្វើការនៅកន្លែងស្ទូងចឹងទៅ គាត់ទៅមើលកន្លែងហ្នឹង ដូចថាខ្ញុំទៅដកចឹងទៅគាត់ទៅអង្គុយនិយាយលេងពីនេះពីនោះចឹងទៅ ហើយយើងចេះតែធ្វើទៅ ។

ដានីៈ មនុស្សគាត់យ៉ាងម៉េចដែរ មនុស្សគាត់?

ជនៈ ខ្ញុំនិយាយដូចថា មនុស្សបើយើងនិយាយថា គាត់អាក្រក់ក៏ថាបានថាគាត់មិនអាក្រក់ក៏បាន ព្រោះគាត់ដូចគេហៅថា ជានារីខ្មែរមិនរើសអើងអីទេ ការងារអីទេ គាត់ជាអ្នកស្រែសុទ្ធ ហើយតាមមើលគាត់ តាំងពី អុំ ស៊ិយអីគាត់ចេះទាំងអស់គេគាត់ហើយរូបសម្បត្តិគាត់ក៏ជាអ្នកស្រែដែរ ។

ដានី: ហើយកន្លែងភ្នំទ្រយោងហ្នឹងអីពូតាំងពីឆ្នាំណាមក កន្លែងមន្ទីរសន្តិសុខភ្នំទ្រយោង?

ជនៈ កាលហ្នឹងខ្ញុំបានទៅ គេបញ្ជូនទៅកន្លែងដកស្ទូងហ្នឹងហើយពូស្ទូវគេនិយាយដែលតែយើងមិនបានចាប់ភ្លឹកអាម៉េចអាម៉ាទេ ។

ដានី: ពូគេនិយាយថាយ៉ាងម៉េច?

ជនៈ ពូគេនិយាយថា មន្ទីរសន្តិសុខហ្នឹងនៅភ្នំទ្រយោងហ្នឹងហើយតែមិនដឹងនៅកន្លែងណាអត់ដឹងទេ ។

ដានី: ភ្នំទ្រយោងហ្នឹងឆ្ងាយទេ?

ជនៈ ខ្ញុំអត់ស្គាល់ទេ ស្គាល់តែភ្នំលៀបហ្នឹង ភ្នំលៀបហ្នឹងស្គាល់កន្លែងផ្ទះនៅហ្នឹងទៀត ភ្នំទ្រយោងហ្នឹងមិនដឹងជាកន្លែងត្រង់ណា ។

ដានី: ចឹងអ៊ីឈ្មោះ ណុញ ឈ្មោះ ថា អីសព្វថ្ងៃគាត់នៅណា?

ជនៈ បែកគ្នាចឹងអត់មានដឹងថានៅខាងណាអីខាងណាទេ អត់ដែលពូស្ទូវទេ ។

ដានី: អត់ដែលពូ?

ជនៈ បាទ!មិនដឹងជាគាត់នៅត្រង់ណាអីត្រង់ណា?

ដានី: ចុះបន្ទាប់ពី ហ៊ិន គណៈតំបន់គេចាប់ទៅមានពីណាឡើងមកជំនួស?

ជនៈ មិនដឹងជាពួកណាឡើងជំនួសទេ ខ្ញុំអត់ដឹងទៀត គណៈតំបន់គណៈអីហ្នឹងអត់ដឹងទេ តែដឹងៗតែយាយ ចែមមួយទេ យាយ ចែមហ្នឹងគាត់នៅខាងស្រុកណាស់ ។

ដានី: ចឹងអ៊ីមានប្រសាសន៍មុនហ្នឹង ពេលអ៊ីទៅប្រជុំនៅសាលាស្រុកហើយគេចាត់តាំងឲ្យអ៊ីទទួលខុសត្រូវខាងទំនប់ត្រពាំងថ្ម?

ជនៈ បាទ!អាហ្នឹងដូចថាគេហៅប្រជុំចឹងគេឲ្យខ្ញុំប្រជុំ ដើម្បីឲ្យឡើងមកប្រជុំហ្នឹងឲ្យខ្ញុំរៀបចំកំលាំងហ្នឹងយកទៅជីកដីត្រពាំងថ្មហ្នឹងឯង ។

ដានី: បាទ ។

ជនៈ ហើយដល់ចឹងទៅខ្ញុំគេហៅចឹងខ្ញុំក៏ឡើងមកផុតមក ។

ដានី: ឡើងមកណា?

ជនៈ ឡើងមកត្រពាំងថ្មហ្នឹង ឡើងមកជីកដីនៅហ្នឹងទៅ ។

ដានី: ចឹងកាលហ្នឹងអ៊ីអាចរៀបរាប់ កន្លែងអ៊ីមកហ្នឹងដូចថាអ៊ីទទួលអីយ៉ាងម៉េច ថាក្រុមរបស់អ៊ីមានគ្នាប៉ុន្មាននៅកន្លែងណាអ៊ី?

ជន: បាទ!ក្រុមខ្ញុំហ្នឹងចាំមើល វាក្នុងមួយក្រុមហ្នឹងមានគ្នា១០នាក់ ។

ដានី: បាទ ។

ជន: ហើយគេឲ្យខ្ញុំទទួលហ្នឹងវាបីក្រុម បីក្រុមហ្នឹងអាបណ្តោយមកខាងលិចហ្នឹងបីក្រុមហ្នឹងគេឲ្យជីកមួយក្រុម៥ម៉ែត្រ មួយក្រុម៥ម៉ែត្របណ្តោយ ៥ម៉ែត្រៗហើយលើកឲ្យបានកំពស់៣ម៉ែត្រ គេដាក់ផែនការចឹង ។

ដានី: បាទ ។

ជន: កំពស់៣ម៉ែត្រហើយខ្ញុំក៏នាំគ្នាលើកដល់លើកទៅក្រុមខ្ញុំហ្នឹង ជួនថ្ងៃខ្លះលើកអត់បានទេ អត់បានគេហៅឡើងកសាងដល់ចឹងទៅចឹងទៅឥឡូវពង្រឹងគោលជំហរបន្តទៀត ហើយនាំគ្នាប្រជុំចឹងទៅក៏ធ្វើទៀត ជួនបានសម្រេចក្នុងរយៈ៥ម៉ែត្រហ្នឹងណាស់ ៥ម៉ែត្រហ្នឹងប៉ុន្មានថ្ងៃដូចជាប៉ុន្មានទេនេះ ដូចជាមួយអាទិត្យហ្នឹងគ្នា១០នាក់ហ្នឹង ឲ្យហើយក្នុង៥ម៉ែត្រហ្នឹង មួយកង់ៗ ។

ដានី: អ្នកដែលហៅក្រុមអ៊ីមកកសាងហ្នឹងពីណាគេមកហៅ?

ជន: កាលហ្នឹងតា ក្រុក ។

ដានី: តា ក្រុក ហៅមកកសាង?

ជន: ដូចថាតា ក្រុក គាត់ហៅមកប្រជុំអីចឹងណាស់ ។

ដានី: ចឹងតា ក្រុក គាត់នៅកន្លែងទំនប់និងដែរ?

ជន: បាទ! តា ក្រុក គាត់នៅ ។

ដានី: ទំបន់ហ្នឹងពីណាជាអ្នកគ្រប់គ្រងធំ?

ជន: អ្នកគ្រប់គ្រងធំតាមមើលស្រុក ស្រុកព្រះនេត្រព្រះនេះឯង តា អាត តា ម៉ោង ទេមិនមែនទេ គណៈតំបន់ទេ គ្រាន់តែថាក្នុងមួយស្រុកៗវាមានចល័តស្រុកអីចឹងទៅ ។

ដានី: អ៊ីទៅលើកពីឆ្នាំណាដល់ឆ្នាំណា?

ជន: យូរដែលហ្នឹងចង់ជិតមួយឆ្នាំដែរ មិនដឹងជាលើកពីឆ្នាំណាដល់ឆ្នាំណាទេនេះ ខ្ញុំអត់ចាំដែរ ។

ដានី: លើកមុនគេចាត់អ៊ីឲ្យទៅស្ពានស្រែងឬមួយក្រោយមកទៀត?

ជន: បាទ ។

ដានី: លើកទំនប់នៅត្រពាំងថ្មហ្នឹង លើកមុនពេលអ៊ីទៅគ្រប់គ្រងចល័តនៅស្ពានស្រែងឬក៏លើកក្រោយ?

ជន: បាទ!ទេ លើកមុនៗគេចាត់ខ្ញុំទៅស្ពានស្រែងហ្នឹង អាហ្នឹងគេចាប់ពួកតា ក្រុក ហើយ ។

ដានី៖ ចឹងទៅលើកមុន?

ជន៖ បាទ ។

ដានី៖ បានមួយឆ្នាំដែរ?

ជន៖ ដឹងបានមួយឆ្នាំឬអត់ទេហ្នឹង ។

ដានី៖ កាលហ្នឹងអ៊ីគ្រប់គ្រងកំលាំងប្រហែលជាប៉ុន្មាន?

ជន៖ កាលហ្នឹងគ្រប់គ្រងកំលាំងប្រហែលជា៣០ នាក់អីចឹង ។

ដានី៖ ចឹងអ៊ីមើលការខុសត្រូវ៣០ នាក់ហ្នឹងទៅ?

ជន៖ បាទ! មើលតែដល់ក្រោយមកទៀតក៏ដូចថាវាទៅសល់ប្អូនដប់នាក់អីចឹងណាស់ ។

ដានី៖ បាទ ។

ជន៖ វាអត់ទៀងទាត់ ទៅមុនដំបូងកំលាំងច្រើនដែរ ។

ដានី៖ ចឹងអ៊ីមានប្រសាសន៍មួយទៀតថា យួនជិតចូលមកខាងខ្មែរក្រហមគេប្រជុំរកអ្នកស្ម័គ្រចិត្តទៅព្រំដែនណាស់ កាលហ្នឹងពីណាគេជាអ្នកប្រជុំ ប្រជុំនៅកន្លែងណាទៅ?

ជន៖ អាហ្នឹងកន្លែងយាយ ចែម នេះឯង ។

ដានី៖ កន្លែងយាយ ចែម កាលហ្នឹងគេប្រជុំយ៉ាងម៉េច កាលហ្នឹង?

ជន៖ គេប្រជុំថា អ្នកណាស្ម័គ្រទៅវ៉ៃយួន ។

ដានី៖ តែប្រជុំគេហៅពីណាខ្លះមកប្រជុំហ្នឹង?

ជន៖ បាទ! ច្រើនណាស់ តាំងពីប្រធានក្រុមប្រធានអីគេមកពេញទាំងអស់មិនដឹងថាមកពីខាងណាខាងណីទេ តាំងពីទ័ពស្រុកទ័ពអីគេដឹងមកទាំងអស់ ។

ដានី៖ គ្នាច្រើនទេ?

ជន៖ ច្រើនពេញម៉ាផ្ទះធំ ។

ដានី៖ ពេញម៉ាផ្ទះឬពេញម៉ាវាល?

ជន៖ អត់ទេ ពេញផ្ទះតែផ្ទះធំ ។

ដានី៖ ប្រជុំក្រោមផ្ទះឬលើកផ្ទះ?

ជន៖ លើផ្ទះ ។

ដានី៖ ប្រជុំលើផ្ទះ?

ជន៖ បាទ ។

ដានី៖ អ្នកដែលដឹកនាំប្រជុំ?

ជន៖ បាទ!យាយ ចែម ហ្នឹងឯង ។

ដានី: យាយ ចែម?

ជន: បាទ ។

ដានី: យាយ ចែម ម្នាក់ឯងទេ?

ជន: យី!មានគ្នាទៀត ។

ដានី: ពីណាខ្លះទៀត?

ជន: មិនដឹងជាពីណាខ្លះ ខ្ញុំគ្រាន់តែដឹងច្បាស់ថា យាយ ចែ ម្នាក់ ។

ដានី: ពេលប្រជុំហ្នឹង អឹមាននៅចាំថ្ងៃខែឆ្នាំទេ?

ជន: អត់ទេ ។

ដានី: បានន័យប្រជុំបានរយៈពេលប៉ុន្មានបានយួនចូល?

ជន: ពេលហ្នឹងយួនកំពង់តែបញ្ចូនទ័ពទៅហើយ មិនដឹងជាយ៉ាងម៉េចទេ ។

ដានី: បានប៉ុន្មានឆ្នាំប៉ុន្មានខែទៅបានយួនចូលមកយើងរត់?

ជន: មិនដឹងជាប៉ុន្មានទេ ក្មួយពេលហ្នឹង ពេលហ្នឹងយើងនៅកំពង់ទឹកទេ ដល់គោកនេះបានយើងរត់ កាលនៅកំពង់ទឹកហ្នឹងអត់ទេ យើងកំពង់ដកស្ទូង ។

ដានី: កំពង់ដកស្ទូង?

ជន: បាទ ។

ដានី: កំពង់ដកកំពង់ស្ទូងហ្នឹងគាត់មានប្រជុំហើយនៅអាហ្នឹង?

ជន: បាទ!!! ។

ដានី: ប្រជុំនៅប្រជុំរកអ្នកស្មគ្រ័ចិត្តហើយនៅ?

ជន: កំពង់ដកស្ទូងហ្នឹង ឡើងពីហ្នឹងមកគាត់ប្រជុំហើយ ។

ដានី: គាត់ប្រជុំ?

ជន: បាទ!ប្រជុំហើយ ។

ដានី: គាត់ប្រជុំគាត់មាននិយាយយ៉ាងម៉េចខ្លះទៅអឹមាននៅចាំទេ?

ជន: ខ្ញុំដូចជាពិបាកចាំទៀត រឿងប្រជុំហ្នឹងគាត់ប្រជុំថា ឥឡូវមិត្តណាស្មគ្រ័ចិត្តវ៉ៃយួនមើលលើកដៃហើយក៏នាំគ្នាលើកទៅណាស់ ។

ដានី: លើកគ្នាច្រើនទេ?

ជន: បាទ!លើកទាំងអស់គ្នា លើកចឹងទៅគាត់ថាបាន ដល់ក្រោមមកទៀតមកក៏ស្ងាត់ទៅយើងធ្វើការនៅធ្វើការដដែលទៅ ។

ដានី: លើកទៅហើយគាត់អត់យកទៅទេ?

ជនៈ	អត់មានយកអ្នកណាម្នាក់ទេ ។

ដានីៈ	អត់មានយកពីណាម្នាក់ហើយគាត់និយាយថាម៉េច?

ជនៈ	គាត់អត់មាននិយាយអីទៀតទេ គាត់ហៅហ្នឹងគាត់អត់មានថាម៉េចទៀតអត់ ។

ដានីៈ	ចឹងអឺមានប្រសាសន៍ថា គាត់សសើរថាយើងម៉េច?

ជនៈ	អរ!សសើរថាយើងលើកដៃទាំងអស់គ្នាចេះ អាហ្នឹងបើថាយកទៅគឺទៅតែម្តង ព្រោះយើងលើកដៃហើយ យើងសន្និដ្ឋានថាយើងទៅ គាត់សប្បាយចិត្តថាយើងលើកដៃ ។

ដានីៈ	ដល់ហើយគាត់អត់មានយកទេ ឲ្យយើងនៅធ្វើការធម្មតា?

ជនៈ	បាទ!ឲ្យធ្វើការធម្មតាវិញ ។

ដានីៈ	ដល់ពេលបន្ទាប់មកអឺទៅធ្វើការនៅណាវិញទៅ?

ជនៈ	បាទ!នៅកន្លែងអាដែលវិញ ។

ដានីៈ	កន្លែងដដែលនៅណាទៅ?

ជនៈ	នៅភ្នំលៀបវិញ កន្លែងដកស្ទូងកំពង់តែប្រូតហ្នឹង ស្រូវកំពស់ៗនេះហើយវាលិចទឹក ។

ដានីៈ	បាទ ។

ជនៈ	ផ្ទៃហើយទុំហើយវាលិចទឹកយើងចេះតែខំប្រូត ។

ដានីៈ	ប្រូតស្រូវហ្នឹងនៅមុំណាប្រូតស្រូវហ្នឹង?

ជនៈ	ត្រង់ស្ពានអាស្ពានមួយហូរទៅចេះ អាស្ពានយើងចុះពីភ្នំលៀបទៅមានស្ពានមួយធំ ។

ដានីៈ	បាទ ។

ជនៈ	ស្ពានហ្នឹងមានប្រឡាយមួយទៅពីក្រោមហ្នឹងតែម្តង ។

ដានីៈ	អឺជាអ្នកដឹកនាំកំលាំងប្រូតហ្នឹង?

ជនៈ	ខ្ញុំថាដឹកក៏ថាបានថាប្រូតជាមួយគ្នាក៏ថាបាន ថាអ្នកនាំកំលាំងចុះក៏បាន ។

ដានីៈ	បាទ ។

ជនៈ	តែមិនមែននាំកំលាំងទាំងអស់ហ្នឹងទេ តាមក្រុមខ្ញុំទេ ។

ដានីៈ	ចឹងអឺកាលហូបចុកអីយ៉ាងម៉េចដែរ កាលសម័យតា ក្រក ហើយសម័យក្រោយមកពួកនិរតីយាយ ចែម ណុញអីចូលមកយ៉ាងម៉េចដែរ?

ជនៈ	ក្មួយអើយបើនិយាយរឿងហូបចុកហ្នឹង វាពិបាកនិយាយមែននិយាយថាម៉េចទេ អានេះនិយាយជាការស្មោះត្រង់ហើយ ជាការពិតកាតូយើងប៉ុននេះមានអង្ករពីវែក អង្ករបាយពីវែកបបរយើងហ្នឹង ហ្នឹងសម្រិតយកសាច់ហ្នឹងបានប្រហែលជាប៉ុណ្ណឹង កាថូប៉ុណ្ណឹងកំពស់ហ្នឹងហ្នឹងគ្នា៥ទៅ៦នាក់ មួយកាថូហ្នឹងហើយយកមក ។

ដានី៖ ហូបគ្នា៥នាក់មួយកាថូហ្នឹង?

ជន៖ មិនមែន៥ទេ ជួន៦នាក់ ៧នាក់ចឹងទៅ អាណាគេធំទៅគេបានច្រើនទៅ តែគ្រាន់តែទឹកវាច្រើន ។

ដានី៖ ហូបតែបបរចឹង?

ជន៖ បាទ ។

ដានី៖ មានដែលបានហូបបាយទេ?

ជន៖ ទេ ទាល់តែគេទៅប្រជុំមួងម៉ាយាមអីចឹង ក៏គេដាំបាយហូបមួយដងមួយយាមចឹងដែរ គេប្រជុំណាស់ ។

ដានី៖ ចឹងតាំងពីឆ្នាំ៧៥មកហូបបបរចឹងតែរហូត?

ជន៖ បាទ!៧៥អត់មានបបរទេ ដល់៧៧នេះបានបបរខ្លាំង កាល៧៦មាននៅមានបាយមានបបរណាស់ ។

ដានី៖ បាទ ។

ជន៖ ដល់៧៧ហ្នឹងគ្មានទេ មានតែបបរ ។

ដានី៖ ៧៧ពេលដែលនិរតីមកហ្នឹង?

ជន៖ បាទ!ទាំងបស្ចិមមកទាំងនិរតីមកសុទ្ធតែបបរគេឲ្យបបរទាំងអស់គ្នា ។

ដានី៖ ចឹងអ៊ំមានដឹងមូលហេតុយ៉ាងម៉េចបានជាគេឲ្យយើងស៊ីបបរចឹង?

ជន៖ បាទ!មិនដឹងជាមូលហេតុយ៉ាងម៉េច គេថាវាអត់យើងត្រូវសន្សំសំចៃ សន្សំសំចៃមិនដឹងជាមានន័យយ៉ាងម៉េចទេ ។

ដានី៖ អត់ហ្នឹងយ៉ាងម៉េចយើងធ្វើស្រូវអត់កើត?

ជន៖ កុំនិយាយថា មិនកើត តែមិនដឹងថាយ៉ាងម៉េចឲ្យទៅជាអត់បានថាខ្ញុំឆ្ងល់ តែយើងមិនដឹងជាធ្វើយ៉ាងម៉េច ។

ដានី៖ ចឹងអ៊ំកាលហ្នឹងយើងជាគណៈឃុំដែលយើងអត់មានដឹងមូលហេតុទេ?

ជន៖ អត់ទេ បាទ គ្មានដឹងស្អីបន្តិចទេ គ្មានដឹងថាមូលហេតុអីៗ គណៈឃុំនោះបើយើងនិយាយទៅគណៈឃុំគ្មានន័យខ្លឹមសារអីទេ អាហ្នឹងខ្ញុំនិយាយថា តាមការចាត់តាំងចឹង ចាត់តាំងដូចជាខ្ញុំដូចជាមនុស្សទីងមោងហ្នឹង មានទៅដឹងអី យើងចេះតែធ្វើៗទៅបើគេឲ្យយើងធ្វើហើយ ចេះតែធ្វើៗទៅ ។

ដានី៖ ចឹងអ៊ំហូបដូចគេឯងដែលឬមួយឃុំមានរបបផ្សេង?

ជន៖ អត់មានទេ គេតាមជានរហូតទាំងអស់គ្នាហ្នឹង ។

ដានី៖ ចឹងខាងថា ខាង ណុញ គេហូបអី?

ផន៖ អត់ដឹងគេទេ ខ្ញុំនេះហូបតែបបរសុទ្ធហើយ ខាងគេនោះខ្ញុំមិនដឹងថាគេហូបយ៉ាងម៉េច ព្រោះហូបអត់ដឹងទេ ។

ដានី៖ ចឹងគេអត់មានមកហូបជាមួយយើងទេ?

ផន៖ ជួនគេហូបជួនគេអត់មកហូបជាមួយយើងទេ គេហូបផ្សេងតែរបៀបម៉េចយើងមិនហ៊ានថាការមិនពិត ។

ដានី៖ ជំនាន់តា ក្រក គាត់ហូបយ៉ាងម៉េច?

ផន៖ អាហ្នឹងហូបដូចខ្ញុំដែលហូបជាមួយប្រជាជនដូចគ្នា បបរដូចគ្នា តែត្រង់គាត់ហូបយ៉ាងម៉េចទៀតអត់ដឹង ដល់ពេលហ្នឹងចេះតែបែកៗគ្នាទៅ ខ្ញុំទៅនេះទៅ គេទៅនោះទៅ ខ្ញុំហូបតែបបរហ្នឹងដែរ ។

ដានី៖ ចឹងរឿងប្រជាជនមានខុសមានអី អ៊ំមានដឹងថាប្រជាជនមានខុសត្រូវចាប់ត្រូវអីទេ?

ផន៖ អាហ្នឹងចេះតែមានដឹងដែលហើយ ការចាប់ចងហ្នឹង តែមិនដឹងថាគេចាប់ប្រភេទយ៉ាងម៉េចរឿងខុសជួនគ្នាទៅជីកដំឡូងចឹង ដូចថាចោរចឹង អានេះចឹងចុះណាស់ ថាចោរចឹងហើយចាប់តែមិនដឹងជាយ៉ាងម៉េច ។

ដានី៖ ចាប់ធ្វើទារុណកម្មមានវ៉ៃអីដែរ?

ផន៖ ជួនខ្លះគេហៅថា ក្មួយឯងក៏ប្រជាជនខ្ញុំក៏ជាប្រជាជន ។

ដានី៖ បាទ ។

ផន៖ ប្រជាជនមានឃុំគេចាត់តាំងអាហ្នឹងហើយទៅវ៉ៃ ដូចថាគេឈឺចាប់ណាស់ គេធ្វើហាមអីចឹងទៅគេថាយកចិត្តទុកដាក់ជាមួយឃុំអីហ្នឹង វ៉ៃគ្នានោះទៅវ៉ាច្រើនចឹង សុទ្ធតែគ្នាឯងទេវ៉ៃ ថាឲ្យឃុំទៅវ៉ៃមិនវ៉ៃទេ គ្នាឯងហ្នឹង គេហៅយកចិត្តទុកដាក់ឃុំហ្នឹង ។

ដានី៖ ជាឈ្លប?

ផន៖ ហ្នឹងហើយជាឈ្លប អាហ្នឹងហើយច្រើនវ៉ៃ ។

ដានី៖ ចឹងអ៊ំបែកឆ្នាំ៧៩ពេលហ្នឹងយួនចូលហ្នឹង យ៉ាងម៉េចអ៊ំរត់ជាមួយពីណាខ្លះកាលហ្នឹង?

ផន៖ គ្នាច្រើនណាស់អត់មានចាំពីណាម្នាក់ទេ មកជួបក្មួយឯងមកចឹងបានមួយភ្លេច ក្មួយឯងបាត់ខ្ញុំក៏ទៅទៀតទៅ ។

ដានី៖ មានរត់មកជាមួយយាយ ចែមដែលឬមួយអត់ទេ?

ផន៖ អត់ទេ យាយ ចែម ផ្សេង យាយ ចែម គាត់រត់ផ្សេង ។

ដានី៖ ចឹងអ៊ំរត់ជាមួយពីណាខ្លះ?

ជន: ខ្ញុំរត់ជាមួយពួកទ័ពគេ ។

ជានី: អត់មានរត់ជាមួយ ណុញ ជាមួយ ថា អីទេ?

ជន: មុនដំបូងរត់ជាមួយគ្នា ដល់ក្រោយមកវាបែក មកដល់ដើមថ្នល់នេះបែកគ្នាអស់ ។

ជានី: មកដល់ណា?

ជន: ដើមថ្នល់នេះ មកដល់ផ្លូវជាតិលេខ៥នេះ ហ៊ោយប៉ែតនេះបែកគ្នាតែម្តង ខ្ញុំក៏បែកទៅផ្សេង គាត់ក៏បែកទៅផ្សេង ។

ជានី: ដើមថ្នល់?

ជន: បាទ! នៅខាងដើមថ្នល់ ។

ជានី: នៅខាងដើមថ្នល់?

ជន: បាទ! ខាងដើមថ្នល់ ។

ជានី: ក៏បែកទៅ?

ជន: បែកអានោះបែកហើយចេះតែទៅហើយ អ្នកណាស្គាល់ណាចេះតែទៅហ្នឹងហើយ ។

ជានី: អ៊ំមកនៅនេះឆ្នាំណា?

ជន: ខ្ញុំថា ៩៣ហ្នឹងហើយ៩៣ហើយ ព្រោះមានតុភូមិនិវត្តន៍ខ្ញុំមកជំរំនេះ“សាយអេក”នេះ ។

ជានី: ចឹងឆ្នាំណាអ៊ំទៅចូលជំរំ?

ជន: ចូលតាំងពីអើយមកតែម្តង តាំងពីបែកមករត់មកហ្នឹងចូលជំរំ មុនដំបូងចូលជំរំព្រៃមាន់នេះ មិនមែនជំរំនេះអាហ្នឹងដូចថាគេមកនៅស្នាក់ ។

ជានី: បាទ ។

ជន: បាទ! ព្រៃមាន់បានចូលមកជំរំគ្រួសក្រហម មកដល់ជំរំគ្រួសក្រហមបានមកជំរំសាយអេកនេះ បានត្រឹមជំរំសាយអេកទេ ។

ជានី: ចឹងអ៊ំទៅជំរំហ្នឹងមានបំណងយ៉ាងម៉េច?

ជន: បាទ! អានេះវាអត់មិនដឹងជារកអី ថាទៅជំរំហ្នឹងបានអង្ករហូបមានគំនិតមួយតែប៉ុណ្ណឹងឯង ។

ជានី: ចឹងនៅឆ្នាំ៩៣ ធ្វើមាតុភូមិនិវត្តន៍ហើយយ៉ាងម៉េចបានជាអ៊ំមកនៅហ្នឹង អ៊ំមិនទៅនៅខាងក្នុងវិញ?

ជន: បាទ! គេរើនោះ ខ្ញុំនៅ“យាយអត”នៅខាងយើងនោះ ។

ជានី: ខាងណា?

ជន: ខាង“យាយអត” ។

ជានី: យាយអតនៅណាទៅ?

ជន:	យាយអតនៅជិតផ្លូវជាតិលេខ៥ហ្នឹង ប៉ោយប៉ែតនេះណាស់ ។

ជានី:	បាទ ។

ជន:	យាយអតយើងនេះ ។

ជានី:	ស្រុកអីគេហ្នឹង?

ជន:	ស្រុកប៉ោយប៉ែត ។

ជានី:	យាយអតហ្នឹង?

ជន:	បាទ! ស្រុកប៉ោយប៉ែតហ្នឹងឯង ។

ជានី:	៩៣ មកនៅយាយអតហ្នឹង?

ជន:	បាទ! អាហ្នឹងគេមាតុភូមិនិវត្តន៍ណាស់ ។

ជានី:	បាទ ។

ជន:	គេចែកដីចែកអីហើយដល់គេរ៉ៃគ្នាខ្លាំងខ្ញុំមិនដឹងទៅណាមកនិងគេដែលទៅ យើញគេមកខាងនេះមកដែរ ។

ជានី:	មកនៅហ្នឹងរហូតទាល់តែឥឡូវទៅ?

ជន:	បាទ! បំរ៉ុងចូលជំរំស្អីនោះវិញទេ អាជំរំសាយអេកហ្នឹងដល់អត់មានចូលទៅក៏មកនៅនេះនៅ ។

ជានី:	ចឹងអ៊ំមានធ្លាប់ទៅលេងស្រុកកំណើតអីដែលអត់?

ជន:	អត់ អត់ដែលបានទៅសោះ អត់រលីងតែម្ដង គិតថាបើសិនជាទៅមិនដឹងជាមានស្អីឥឡូវប្អូនក៏មិនដឹងនៅណា ហើយដីធ្លីអីគេយកអស់ហើយអត់មានអីទេ ។

ជានី:	ចឹងអ៊ំមានដែលទៅលេងខាងព្រះនេត្រព្រះអីទេ?

ជន:	អត់ អត់ដែលបានទៅទេ ។

ជានី:	យ៉ាងម៉េចបានជាអ៊ំមិនដែលទៅ?

ជន:	ជួនទៅដែលតែទៅមិនបានចូល ទៅលេងតែបងប្អូននៅម៉ាជួរដងស្ទឹងក្រឡាញ់ទៅ ។

ជានី:	ខាងដងស្ទឹងក្រឡាញ់ខាងសៀមរាបអីហ្នឹង?

ជន:	បាទ ។

ជានី:	ខាងទិម៉ាល់ហ្នឹងមិនមែនទេ?

ជន:	បាទ! បងប្អូននៅហ្នឹង ។

ជានី:	បងប្អូនខាង?

ជន:	ខាងប្រពន្ធ ។

ជានី:	មានធ្លាប់ទៅខាងហ្នឹងដែរ?

ផនៈ ទៅ ។

ដានីៈ ចឹងបើសិនជាអ៊ីទៅលេងខាងព្រះនេត្រព្រះទៅលេងអីអ៊ីទៅទេ?

ផនៈ អត់មានអីទេ ។

ដានីៈ បើសិនជាមានការអីត្រូវទៅអីអ៊ីទៅដែលអត់?

ផនៈ បើមានការត្រូវតែទៅ ។

ដានីៈ អ៊ីអត់មានខ្វាចមានអីទេ ព្រោះអ៊ីធ្លាប់ធ្វើជាគណៈឃុំ?

ផនៈ អាហ្នឹងមានខ្លាចអីយើងមានទៅធ្វើអីគេ គួរឲ្យគេព្រឺព្រួចអី ។

ដានីៈ បើសិនជាមានការអីត្រូវមានដំណើរទៅខាងឃុំព្រះនេត្រព្រះអីអ៊ីទៅអត់មានខ្លាចអីទេ?

ផនៈ ទៅដែលទៅធ្វើបុណ្យទៅអីដែលហ្នឹង ។

ដាវ៉ាៈ ចឹងធ្លាប់ទៅទេ?

ផនៈ ធ្លាប់ទៅដែលទៅធ្វើបុណ្យអី ។

ដាវ៉ាៈ នៅព្រះនេត្រព្រះ?

ផនៈ បាទ! នៅព្រះនេត្រព្រះ ។

ដាវ៉ាៈ ពេលទៅមានជួបណាខ្លះពេលទៅហ្នឹង?

ផនៈ បាទ!ដូចជាអត់មានបានជួបអីគ្នាស្គាល់អីអត់ មានច្រើនពួកថ្មីៗដែលចាស់ៗ ។

ដាវ៉ាៈ ពេលដែលទៅធ្វើបុណ្យហ្នឹងមានអ្នកណាស្គាល់អ៊ីថា ជាតា ផនអីចឹងដែរ?

ផនៈ មានស្គាល់ដែរ ។

ដានីៈ មានគេរាក់ទាក់អ៊ីដែលឬយ៉ាងម៉េច?

ផនៈ រាក់ទាក់ដែរ តែថាយើងវាក្រីក្រទៅវាមិនបានទៅលេង វាមិនសូវបានទៅញឹកញាប់អីទេ យូរៗទៅម្ដង តែបើមានបុណ្យអីទៅដែរ ។

ដាវ៉ាៈ ចឹងពូមានស្គាល់ពូ សល់ទេ?

ផនៈ សល់!! ។

ដានីៈ សល់ កាលពីសម័យបីឆ្នាំគាត់នៅក្មេងដែរ គាត់ធ្លាប់ធ្វើជានិរសានៅឃុំទានកាំនៅឃុំរហាល ហើយក្រោយមកគាត់ទៅធ្វើជាអ្នកយាមនៅភ្នំទ្រយោងអីចឹង កាលពីបួនប្រាំមុនគាត់ធ្លាប់ជិះឡានគាត់ហ្នឹង មករកស៊ីឈ្នួលកាច់ពោតកាច់អីហើយគាត់បានជួបអ៊ីនៅតាមផ្លូវ គាត់ស្រែកហៅអ៊ី?

ផនៈ មិនដឹងជាយ៉ាងម៉េចខ្ញុំមិនបានចាប់ភ្លឹក ព្រោះឯងចាស់ទៅមើលមិនស្គាល់ គេហៅយ៉ាងម៉េចដូចកាលណាច្បាស់ហើយគេបញ្ជាក់អាហ្នឹងបានអាចដឹងបាន ។

ដានី៖ អ៊ឹខ្ញុំដូចជាអស់សំនួរអីត្រូវសួរនាំទៀតហើយ ចឹងអ៊ឹមានអីចង់បញ្ជាក់បន្ថែមដែលពួកខ្ញុំមិនបានសួរនាំអ៊ឹអី?

ផន៖ អ! វាអត់មានស្អីទៀត អត់មានស្អីបញ្ជាក់ ។

ដានី៖ ចឹងខ្ញុំអរគុណអ៊ឹច្រើន ។

ផន៖ បាទ ។

**ចប់**